## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ជូ ម៉េងលី**

ណែនាំដោយ

**លោក ម៉ៅ មុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ជូ ម៉េងលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣ លេខកូដថ្នាក់L៤A៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

លោកឪពុកឈ្មោះ **អ៊ត់ គឹមឈាង** និងអ្នកម្ដាយឈ្មោះ **ពេជ្រ ស៊ីវហៀង**

នាងខ្ញុំសូមសម្ដែងនូវការគោរព  និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនលោកអ្នកមានគុណទាំងទ្វេ ដែលបានផ្ដល់កំណើតដល់រូបកូនឱ្យឃើញពន្លឺថ្ងៃ ដោយលោកទាំងពីរបានលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត សុខចិត្តរងទុក្ខលំបាកគ្រប់បែបយ៉ាងនៅក្នុងការចិញ្ចឹមបីបាច់មើលថែរក្សារូបកូនតាំងតែពីតូចរហូតដល់កូនធំ ផ្ដល់ការអប់រំទូន្មានប្រៀនប្រដៅកូនដើម្បីឱ្យកូនក្លាយជាមនុស្សល្អប្រកបដោយគន្លងធម៌ដើម្បីជាប្រយោជន៍ដល់គ្រួសារ និងសង្គមជាតិ ព្រមទាំងផ្ដល់ការទំនុកបម្រុងគ្រប់បែបយ៉ាងរហូតដល់រូបកូនបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រគ្រប់រូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំផ្ដោតយ៉ាងសំខាន់ទៅលើគុណភាពនៃការអប់រំ បណ្ដាលឱ្យនាងខ្ញុំទទួលបានចំណេះដឹង និងសមត្ថភាពពិតលើមុខជំនាញដែលនាងខ្ញុំបានជ្រើសរើសតាមរយៈទ្រឹស្ដីព្រមទាំងការបញ្ចូលបទ-ពិសោធន៍ក្នុងការអប់រំគោលបំណងឱ្យនាងខ្ញុំទទួលបានភាពជោគជ័យក្នុងការសិក្សា និងអាជីព។

ជាងនេះទៅទៀតនាងខ្ញុំសូមសម្ដែងនូវការដឹងគុណចំពោះលោកសាស្ត្រាចារ្យ **ម៉ៅ មុន្នីណា** ដែលលោកបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ផ្ដល់ដំបូន្មាន ព្រមទាំងធ្វើការកែតម្រូវក្នុងន័យស្ថាបនាលើសៀវភៅសារណារបស់នាងខ្ញុំដើម្បីទទួលបានលទ្ធផលជោគជ័យជាស្ថាពរ។

សូមថ្លែងអំណរគុណជាអនេកដល់លោក **ណារ៉ា ពៅបញ្ញារិទ្ធ** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជាដែលបានផ្ដល់ការណែនាំ ការពន្យល់ ការបកស្រាយ និងជួយសម្របសម្រួលពាក់ព័ន្ធនឹងការរៀបចំស្រាវជ្រាវសរសេរសៀវភៅសារណានេះ។

សូមថ្លែងអំណរគុណចំពោះមិត្តរួមជំនាន់ទាំងអស់ដែលតែងតែលើកទឹកចិត្ត គោរពនិងឱ្យតម្លៃគ្នាទៅវិញទៅមកក្នុងរយៈពេល៤ ឆ្នាំកន្លងទៅនេះ។

ជាចុងក្រោយនាងខ្ញុំ សូមគោរពជូនពរអ្នកមានគុណទាំងទ្វេ ឯកឧត្ដម លោកជំទាវ លោក/លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ឱ្យទទួលបានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងជួបប្រទះតែពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជាបាននិងកំពុងបង្កើតច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឱ្យមានភាពរីកចម្រើន ក៏ដូចជារៀបចំដំណើរការនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយតម្លាភាព សុក្រឹត្យភាព ក្នុងការធានាឱ្យបានទំនុកចិត្តពីសាធារណជន។ ទន្ទឹមនឹងនេះ ដើម្បីបង្កើនជម្រើសដល់វិស័យឯកជន និងរដ្ឋក្នុងការកៀរគរប្រមូលមូលធនមកវិនិយោគក្នុងស្រុក និងក្រៅស្រុក ការបង្កើនកាលានុវត្តភាពវិនិយោគ និងការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ វិស័យមូលបត្រត្រូវបានកំណត់ជាវិស័យអាទិភាពមួយដើម្បីជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់កម្ពុជាឱ្យកាន់តែមានការរីកចម្រើនប្រកបដោយបរិយាបន្ន នវានុវត្តន៍ និងនិរន្តរភាព ដែលមាន **និយ័តករមូលបត្រកម្ពុជា** គឺជាអាជ្ញាធរគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យនេះ។

តាមដំណើរការអភិវឌ្ឍវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជាបានដាក់ចេញផែនការយុទ្ធសាស្ត្រជាច្រើនដើម្បីបង្កើនការយល់ដឹងដល់សាធារណជនឱ្យមានឱកាសស្វែងយល់ អំពីយន្តការ នីតិវិធី និងប្រតិបត្តិការសំខាន់ៗក្នុងវិស័យមូលបត្រ ដែលជាគន្លឹះយ៉ាងសំខាន់សម្រាប់ឱ្យសាធារណជនចូលមកធ្វើការវិនិយោគ។ ការបង្កើនការយល់ដឹងពីវិស័យមូលបត្រនេះ គឺដើម្បីរួមចំណែកក្នុងការការពារសាធារណជនពីការភ័ន្តច្រឡំនានា និងធ្វើការពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងការវិនិយោគក្នុងវិស័យមូលបត្រ ក៏ដូចជាការជំរុញឱ្យមានទំនុកចិត្តពីសាធារណជនមកលើវិស័យមូលបត្រ ឱ្យទទួលបានជោគជ័យលើដំណើរការវិនិយោគ ព្រមទាំងចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់កម្ពុជាឱ្យកាន់តែមានភាពរីកចម្រើនថែមមួយកម្រិតទៀត។

ក្នុងន័យនេះ នាងខ្ញុំបានព្យាយាមសិក្សាស្រាវជ្រាវ និងរៀបចំសរសេរសារណានេះឡើងក្នុងគោលបំណងធ្វើយ៉ាងណាស្វែងយល់ពីយន្តការ និងនីតិវិធីរបស់និយ័តករមូលបត្រកម្ពុជាក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រ ព្រមទាំងការធានាបានសុវត្ថិភាពចំពោះដំណើរការវិនិយោគជូនសាធារណជន និងការធានាឱ្យបានទំនុកចិត្តដល់សាធារណជននៅពេលដែលមានបំណងចូលរួមវិនិយោគក្នុងវិស័យមូលបត្រ ក៏ដូចជាដើម្បីបំពេញលក្ខខណ្ឌនៃការបញ្ចប់សិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។ តាមរយៈការខិតខំសិក្សាស្រាវជ្រាវ និងរៀបចំសរសេរសារណានេះ នាងខ្ញុំក៏បានជួបបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ពិសេសពាក្យបច្ចេកទេសថ្មីៗដែលប្រើប្រាស់តាមច្បាប់និងបទប្បញ្ញត្តិនៅក្នុងវិស័យមូលបត្រ ដោយហេតុថាវិស័យមូលបត្រគឺជាវិស័យហិរញ្ញវត្ថុមួយដែលថ្មីស្រឡាងក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែទោះបីជាមានបញ្ហាប្រឈមមួយចំនួនយ៉ាងនេះក្តី នាងខ្ញុំនៅតែព្យាយាមរៀបចំសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រនេះបានប្រកបដោយជោគជ័យ។

នាងខ្ញុំសង្ឃឹមថា សមិទ្ធផលនេះអាចរួមចំណែក ក្នុងការផ្តល់ពុទ្ធិ និងចំណេះដឹង ព្រមទាំងជាឯកសារជំនួយស្មារតីយ៉ាងសំខាន់សម្រាប់សិស្ស និស្សិត បញ្ញវន្ត អ្នកសិក្សាស្រាវជ្រាវ វិនិយោគិនមូលបត្រ និងសាធារណជនទូទៅ អាចធ្វើការស្វែងយល់បន្ថែមពីប្រធានបទស្តីពី "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" ធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវស្វែងរកចំណេះដឹងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ និងការបណ្តុះ-បណ្តាលធនធានមនុស្សជំនាន់ក្រោយ។

ជាទីបញ្ចប់ នាងខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនានៅក្នុងអត្ថបទសារណោ ដូចជាកំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេជន៍ វេយ្យាករណ៍ និងឃ្លា ល្បះ ពុំបានត្រឹមត្រូវជាដើម និងរង់ចាំទទួលដោយក្តីរីករាយការកែលម្អពីគ្រប់មជ្ឈដ្ឋានទាំងអស់ពាក់ព័ន្ធនឹងសារណោរបស់នាងខ្ញុំ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ៣
៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣
៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........................................ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៤

## ជំពូកទី១
## យន្តការស្ថាប័ននិយ័តករមូលបត្រកម្ពុជា

១.១. មុខងារ និងតួនាទី ភារកិច្ចរបស់និយ័តករមូលបត្រកម្ពុជា ........................................ ៥
១.១.១. ការគ្រប់គ្រង និងការត្រួតពិនិត្យវិស័យមូលបត្រ ........................................ ៥
១.១.១.១. ការគ្រប់គ្រង ........................................ ៥
១.១.១.២. ការត្រួតពិនិត្យ ........................................ ៧
១.១.២. ការអភិវឌ្ឍវិស័យមូលបត្រ ........................................ ៧
១.១.២.១. ការបង្កើតច្បាប់ បទប្បញ្ញត្តិ ........................................ ៧
១.១.២.២. ការអប់រំ និងការបណ្តុះបណ្តាល ........................................ ៨
១.២. រចនាសម្ព័ន្ធថ្នាក់ដឹកនាំ និងរចនាសម្ព័ន្ធបច្ចេកទេស ........................................ ៩
១.២.១. រចនាសម្ព័ន្ធថ្នាក់ដឹកនាំ ........................................ ៩
១.២.១.១. អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ........................................ ៩
១.២.១.២. អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ........................................ ១១
១.២.២. រចនាសម្ព័ន្ធបច្ចេកទេស ........................................ ១២
១.២.២.១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........................................ ១២
១.២.២.២. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ........................................ ១៣

១.២.២.៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ............ ១៤
១.២.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ............ ១៥
១.២.២.៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ............ ១៦
១.២.២.៦. នាយកដ្ឋានកិច្ចការគតិយុត្ត ............ ១៧

## ជំពូកទី២

## យន្តការដោះស្រាយវិវាទ និងបង្ក្រាបការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

២.១.ការទទួលពាក្យបណ្តឹង និងការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ............ ២០
២.១.១. ពាក្យបណ្តឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ ............ ២០
២.១.១.១. ការដាក់ និងទទួលពាក្យបណ្តឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ ............ ២០
២.១.១.២. ចំណាត់ការលើពាក្យបណ្តឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ ............ ២២
២.១.២. ដំណើរការនៃការផ្សះផ្សា និងការដោះស្រាយវិវាទ ............ ២៥
២.១.២.១. ការផ្សះផ្សាវិវាទ ............ ២៥
២.១.២.២. ការដោះស្រាយវិវាទ ............ ២៦
២.២. ការបង្ក្រាបការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ ............ ២៨
២.២.១. ការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ ............ ២៨
២.២.១.១. អំពើល្មើស............ ២៩
២.២.១.២. បទល្មើស ............ ៣០
២.២.២ នីតិវិធីស៊ើបអង្កេត និងការពង្រឹងការអនុវត្តច្បាប់ ............ ៣១
២.២.២.១. ការស៊ើបអង្កេត ............ ៣១
២.២.២.២. ការពង្រឹងការអនុវត្តច្បាប់ ............ ៣២
**សេចក្តីសន្និដ្ឋាន** ............ ៣៤
**អនុសាសន៍** ............ ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យហិរញ្ញវត្ថុមិនមែនធនាគារ គឺជាសរសៃឈាមយ៉ាងសំខាន់ដែលបានដើរតួក្នុងការធានាឱ្យមានកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យរីកចម្រើន ព្រមទាំងរួមចំណែកដើម្បីជំរុញការធ្វើពិពិធកម្ម និងលើកកម្ពស់ការប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ។ វិស័យហិរញ្ញវត្ថុមិនមែនធនាគាររួមមានជាអាទិ៍ វិស័យធានារ៉ាប់រង វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យ និងសវនកម្ម វិស័យអចលនវត្ថុនិងបញ្ចាំ និងរួមបញ្ចូលទាំងវិស័យមូលបត្រ។ ក្នុងនោះវិស័យមូលបត្រ គឺជាវិស័យមួយយ៉ាងសំខាន់ដែលបានរួមចំណែកក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចជាតិតាមរយៈការកៀរគរមូលធនពីសាធារណជន ឬវិនិយោគិនមូលបត្រទាំងក្នុងស្រុក និងក្រៅស្រុក ដើម្បីឆ្លើយតបនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

ដោយមើលឃើញពីសារៈសំខាន់ និងភាពចាំបាច់របស់វិស័យហិរញ្ញវត្ថុក្នុងការទ្រទ្រង់សេដ្ឋកិច្ចជាតិ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាវិស័យមូលបត្រ តាមរយៈការដាក់ចេញ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០" ដែលក្រោយមកត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" និង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" និងកំពុងធ្វើបច្ចុប្បន្នកម្មទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២១-២០៣០" ដើម្បីជាមគ្គុទេសក៍ចង្អុលផ្លូវសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែង។ ជាមួយគ្នានេះ គឺដើម្បីធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុមានដំណើរការប្រកបដោយប្រសិទ្ធភាព ពិពិធភាព ចីរភាព បរិយាបន្ន ស្របតាមការវិវត្តយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យក្នុងការបង្កើតវិស័យមូលបត្រកម្ពុជា។

ផ្អែកតាមគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០៧ គម្រោងអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រោមគម្រោងអភិវឌ្ឍន៍ទីផ្សារមូលបត្រនេះ ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ត្រូវបានរៀបចំ និងអនុម័តឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការ

ជួញដូរមូលបត្រមហាជន។ បន្ទាប់ពីច្បាប់ និងអនុក្រឹត្យត្រូវបានរៀបចំ និងអនុម័តរួច គណៈកម្មការមូលបត្រកម្ពុជាក៏ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់** ដែលកាលនោះឯកឧត្តមជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា បន្ទាប់មកច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យនេះត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ក្នុងគោលបំណងពង្រឹងទំនុកចិត្តក្នុងការវិនិយោគ ក៏ដូចជាជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិ។

ដោយពិនិត្យឃើញពីភាពរីកចម្រើននៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រាជរដ្ឋាភិបាលកម្ពុជាក្រោមអធិបតី-ភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត "អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" តាមរយៈច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/-រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ តាមរយៈច្បាប់នេះ **គណៈកម្មការមូលបត្រកម្ពុជា** (គ.ម.ក.) ត្រូវបានធ្វើការផ្លាស់ប្តូរឈ្មោះទៅជា **និយ័តករមូលបត្រកម្ពុជា** (ន.ម.ក.) និងជាអង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបច្ចុប្បន្នមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ដោយឡែកសម្រាប់ការអនុវត្តមុខងារ និងតួនាទី របស់និយ័តករមូលបត្រកម្ពុជានៅតែបន្តអនុវត្តដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ក្នុងគោលបំណងពង្រឹង និងធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏ដូចជាវិស័យមូលបត្រ ដើម្បីរក្សាឱ្យបានទំនុកចិត្តក្នុងការវិនិយោគតាមរយៈការការពារសិទ្ធិស្របច្បាប់របស់វិនិយោគិន និងធានាឱ្យបានការបោះផ្សាយនិងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមានក្នុងវិស័យមូលបត្រ។ ការលើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងជួយជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យតាមរយៈការទិញមូលបត្រនិងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

តាមរយៈប្រធានបទ "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" ដែលនាងខ្ញុំជ្រើសរើសយកមកធ្វើជាប្រធានបទសារណានេះគឺជាផែនទីបង្ហាញផ្លូវចំពោះការកសាង និងបណ្តុះបណ្តាលសមត្ថភាព ការពង្រីកចំណេះដឹងបន្ថែមជូនដល់សិស្ស និស្សិត បញ្ញវន្ត អ្នកស្រាវជ្រាវ វិនិយោគិនក្នុងវិស័យមូលបត្រ និងសាធារណជន

ទូទៅដែរ។ ជាពិសេសអាចឱ្យសាធារណជនទូទៅធ្វើការស្វែងយល់ចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រឱ្យកាន់តែមានភាពទូលំទូលាយក្នុងការវិនិយោគប្រកបដោយហានិភ័យទាប និងស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រ គឺជាវិស័យហិរញ្ញវត្ថុមួយថ្មីស្រឡាងដែលកំពុងចាប់ផ្តើមមានសន្ទុះនៅព្រះរាជាណាចក្រកម្ពុជាដោយបានរុញច្រានសេដ្ឋកិច្ចជាតិទៅរកភាពរីកចម្រើន និងជឿនលឿន។ ដូច្នេះ ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" នេះត្រូវធ្វើឡើងដោយឆ្លើយតបទៅនឹងសំណួរគតិយុត្តដូចខាងក្រោម៖

១. តើនិយ័តករមូលបត្រកម្ពុជា មានតួនាទី និងភារកិច្ចអ្វីខ្លះនៅក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រកម្ពុជា?

២. នៅក្នុងដំណើរការកិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ តើនិយ័តករមូលបត្រកម្ពុជាត្រូវមានយន្តការ និងនីតិវិធីអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវប្រធានស្រាវជ្រាវនេះ គឺដើម្បីធ្វើជាមគ្គុទេសក៍នាំផ្លូវ និងជាឧបករណ៍ការងារគន្លឹះមួយដែលចូលរួមបង្កើតស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព ជាពិសេសជួយពង្រីក និងពង្រឹងចំណេះដឹងបន្ថែមជូនដល់សិស្ស និស្សិត បញ្ញវន្ត អ្នកស្រាវជ្រាវ វិនិយោគិនមូលបត្រ និងសាធារណជនទូទៅស្របតាមការអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទស្រាវជ្រាវខាងលើនេះ នាងខ្ញុំផ្តោតសំខាន់ទៅលើយន្តការ និងនីតិវិធីរបស់ស្ថាប័ននិយ័តករមូលបត្រកម្ពុជា ពាក់ព័ន្ធនឹងការគ្រប់គ្រង ត្រួតពិនិត្យ អភិវឌ្ឍន៍ និងកិច្ចគាំពារវិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជាដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់និយ័តករមូលបត្រកម្ពុជា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវខាងលើនេះ គឺដើម្បីផ្តល់ជូនសាធារណជន និងវិនិយោគិននៅក្នុងវិស័យមូលបត្រចំណេះដឹងពាក់ព័ន្ធនឹងការវិនិយោគ ការការពារ និងអត្ថប្រយោជន៍នៃការវិនិយោគក្នុងវិស័យមូលបត្រ ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បន្ថែមពីនេះ ការស្រាវជ្រាវនេះក៏ជាកាតាលីករជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាស្របនឹងនិន្នាការសាកល និងតំបន់ ដែលធ្វើយ៉ាងណាលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ នាងខ្ញុំបានសិក្សាស្រាវជ្រាវលើបទដ្ឋានគតិយុត្តរួមមាន៖ ច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ក៏ដូចជាការសាកសួរមន្ត្រីជំនាញនៃនិយ័តករមូលបត្រកម្ពុជាដែលកំពុងបានអនុវត្តការងារផ្ទាល់ដើម្បីស្វែងរកធាតុចូលបន្ថែមសម្រាប់ការរៀបចំសរសេរប្រធានបទនេះឡើង។ បន្ថែមពីនេះនាងខ្ញុំត្រូវបានអនុញ្ញាតឱ្យចូលរួមសិក្ខាសាលាដើម្បីបណ្តុះបណ្តាលសមត្ថភាពពាក់ព័ន្ធនឹងវិស័យមូលបត្រ ពិសេសលើប្រធានបទស្តីពី "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" ដែលបានរៀបចំឡើងដោយនិយ័តករមូលបត្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជាវប្រធានបទខាងលើនេះត្រូវបានបែងចែកជាជំពូកចំនួន ២ រួមមាន៖

ជំពូកទី១៖ យន្តការរបស់ស្ថាប័ននិយ័តករមូលបត្រកម្ពុជា។

ជំពូកទី២៖ យន្តការដោះស្រាយវិវាទ និងបង្ក្រាបការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ។

ក្នុងជំពូកនីមួយៗត្រូវបានចែកចេញជា ២ ផ្នែកផ្សេងទៀតដោយមានការបែងចែកជាចំណងជើងរងបន្តបន្ទាប់ជាច្រើនទៀតដើម្បីជាអំណះអំណាងក្នុងការបកស្រាយខ្លឹមសារនៅក្នុងអត្ថបទតាមផ្នែកនីមួយៗឱ្យបានក្បោះក្បាយព្រមទាំងស៊ីជម្រៅ។

# ជំពូកទី១

# យន្តការស្ថាប័ននិយ័តករមូលបត្រកម្ពុជា

# ជំពូកទី១

# យន្តការស្ថាប័ននិយ័តករមូលបត្រកម្ពុជា

## ១.១. មុខងារ និងតួនាទី ភារកិច្ចរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា សរសេរជាអក្សរកាត់ថា ន.ម.ក. ត្រូវបានបង្កើតឡើងក្រោយពីច្បាប់ស្ដីពីមូលបត្ររដ្ឋ និងច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ត្រូវបានអនុម័ត ដើម្បីធ្វើការគ្រប់គ្រង ត្រួតពិនិត្យ រក្សាសណ្ដាប់ធ្នាប់ទីផ្សារ និងអភិវឌ្ឍន៍វិស័យមូលបត្រឱ្យមានភាពរីកចម្រើន និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមជាតិ ក៏ដូចជាដើម្បីរក្សាឱ្យបានទំនុកចិត្តរបស់វិនិយោគិននៅក្នុងទីផ្សារមូលបត្រ។ និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រតាមរយៈការអនុម័ត និងដាក់ឱ្យអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងជំរុញវិស័យមូលបត្រឱ្យមានការរីកចម្រើន ក៏ដូចជាការគ្រប់គ្រងលើតួអង្គដែលជាក្រុមហ៊ុន ឬបុគ្គលបោះផ្សាយតាមរយៈការផ្ដល់អាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ ដោយឈរលើគោលការណ៍សសរស្តម្ភធំៗចំនួនបួន ដែលរួមមាន ប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងសណ្ដាប់ធ្នាប់។

### ១.១.១. ការគ្រប់គ្រង និងការត្រួតពិនិត្យវិស័យមូលបត្រ

#### ១.១.១.១. ការគ្រប់គ្រង

និយ័តករមូលបត្រកម្ពុជា គឺជាអាជ្ញាធរតែមួយគត់ដែលមានសមត្ថកិច្ចនៅក្នុងការគ្រប់គ្រង ត្រួតពិនិត្យពីដំណើរការវិនិយោគក្នុងទីផ្សាររបស់តួអង្គដែលបានចូលរួមនៅក្នុងវិស័យមូលបត្រតាមរយៈការបង្កើតវិធានប្រតិបត្តិ-ការដើម្បីគ្រប់គ្រង និងធានាឱ្យមានទីផ្សារមួយប្រកបដោយប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងសណ្ដាប់ធ្នាប់។ ទីផ្សារមានប្រសិទ្ធភាព សំដៅដល់ទីផ្សារដែលបើកឱ្យមានការប្រកួតប្រជែងដោយត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ការផ្ដល់ព័ត៌មានសមស្រប និងទាន់ពេលវេលាដល់សាធារណជន។ ចំពោះទីផ្សារប្រកបដោយយុត្តិធម៌ សំដៅដល់ទីផ្សារដែលការពារវិនិយោគិនឱ្យគេចផុតពីអំពើរំលោភបំពាន និងការបោកបញ្ឆោតក្នុងទីផ្សារ ដូចជាការជួញដូរផ្ទៃក្នុង ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ ដូចមានកំណត់ក្នុងច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។ ចំណែកឯទីផ្សារមានសណ្ដាប់ធ្នាប់នៅក្នុងទីផ្សារ សំដៅដល់ការការពារមិនឱ្យមានហានិភ័យជាប្រព័ន្ធកើតមានឡើងក្នុងទីផ្សារ ពោលគឺត្រូវមានប្រព័ន្ធត្រួតពិនិត្យ និងឃ្លាំមើលយ៉ាងហ្មត់ចត់ ដើម្បីការពារសិទ្ធិស្របច្បាប់របស់វិនិយោគិន។ យោងតាមបញ្ញត្តិច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ដែលបានផ្ដល់នូវសិទ្ធិអំណាចដល់និយ័តករមូលបត្រកម្ពុជាក្នុងការអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពលើការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជាតាម

រយៈការកំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ ជូនដល់តួអង្គដែលបានចូលរួមក្នុងទីផ្សារមានដូចជា ប្រតិបត្តិកររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ) ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលចុះបញ្ជី ក្រុមហ៊ុនអន្តរការីមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ក្រុម-ហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនចែកចាយលក់មូលបត្រ ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិ) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ភ្នាក់ងាររក្សាសុវត្ថិភាព ក្រុមហ៊ុនផ្តល់សេវាក្នុងវិស័យមូលបត្រ (ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ សវនកម្ម បកប្រែ វាយតម្លៃ) និងតួអង្គពាក់ព័ន្ធផ្សេងទៀតដែលបានចូលរួមក្នុងទីផ្សារមូលបត្រ។ និយ័តករមូលបត្រកម្ពុជាមិនត្រឹមតែមានមុខងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើតួអង្គដែលចូលរួមក្នុងទីផ្សារតាមរយៈការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់តែប៉ុណ្ណោះទេ សូម្បីតែផលិតផលដែលជាប្រភេទមូលបត្រដែលត្រូវយកមកចុះបញ្ជីជួញដូរក្នុងទីផ្សារដែលមានដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល មូលបត្ររដ្ឋ ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម ការជួញដូរឧបករណ៍និស្សន្ទ ព្រមទាំងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលត្រូវកំណត់ថាជាមូលបត្រ ក៏ស្ថិតក្រោមសមត្ថកិច្ចរបស់និយ័តករមូលបត្រកម្ពុជាផងដែរតាមរយៈការបង្កើតនៅបទប្បញ្ញត្តិដើម្បីធ្វើការគ្រប់គ្រងលើផលិតផលរបស់តួអង្គដែលចូលរួមក្នុងទីផ្សារ និងតម្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជាមុននឹងចាប់ផ្តើមធ្វើអាជីវកម្ម។ ចំពោះការស្នើសុំការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជានេះ គឺដើម្បីឱ្យនិយ័តករធ្វើការពិនិត្យ និងវាយតម្លៃថា តើតួអង្គដែលបានចូលរួមក្នុងទីផ្សារមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ធ្វើការវិនិយោគក្នុងវិស័យមូលបត្រ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានហើយឬនៅ?

ក្នុងករណីដែលតួអង្គចូលរួមក្នុងទីផ្សារមូលបត្រដាក់ពាក្យស្នើសុំប្រកបអាជីវកម្មក្នុងវិស័យមូលបត្រពុំបានគោរពតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជាមានសិទ្ធិក្នុងការបដិសេធ ឬមិនផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ ជូនចំពោះក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលដាក់ពាក្យស្នើសុំដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បន្ថែមពីនេះក្នុងករណីដែលតួអង្គចូលរួមក្នុងទីផ្សារមូលបត្របានទទួលអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជារួចហើយ ប៉ុន្តែពុំបានបំពេញកាតព្វកិច្ចដូចមានបញ្ញត្តិក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន និយ័តករមូលបត្រកម្ពុជាអាចចាត់វិធានការ

ទណ្ឌកម្មណាមួយ ដើម្បីធានាដល់ដំណើរការវិនិយោគ និងអ្នកចូលរួមក្នុងវិស័យមូលបត្រ ក៏ដូចជាការការពារផលប្រយោជន៍របស់វិនិយោគិនដែលបានចូលរួមក្នុងទីផ្សារមូលបត្រ។

**១.១.១.២. ការត្រួតពិនិត្យ**

ក្នុងគោលបំណងដើម្បីធានាបានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព ក្នុងទីផ្សារមូលបត្រ និយ័តករមូលបត្រកម្ពុជាបានត្រួតពិនិត្យ និងតាមដានលើការអនុវត្តកាតព្វកិច្ចរបស់តួអង្គដែលបានចូលរួមក្នុងទីផ្សារមូលបត្រតាមរយៈការត្រួតពិនិត្យលើប្រតិបត្តិការអាជីវកម្ម ការអនុវត្តកាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានសាជីវកម្ម ការត្រួតពិនិត្យលើអភិបាលកិច្ចសាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុជាប្រចាំរបស់តួអង្គទាំងអស់ដែលបានចូលរួមក្នុងទីផ្សារមូលបត្រ។ ការត្រួតពិនិត្យ និងតាមដាននេះ និយ័តករមូលបត្រកម្ពុជានឹងពិនិត្យលើព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដែលត្រូវប្រគល់ជូននិយ័តករមូលបត្រកម្ពុជាជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជាដើម ដោយផ្អែកលើអនុលោមភាពផ្អែកច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានក្នុងវិស័យមូលបត្រ។ បន្ថែមពីលើការត្រួតពិនិត្យ និងតាមដានលើឯកសារ និងព័ត៌មាន ដែលបានផ្តល់ជូនដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយជាប្រចាំ និយ័តករមូលបត្រកម្ពុជាក៏អាចធ្វើការតាមដាន និងចុះត្រួតពិនិត្យដល់ទីកន្លែងផ្ទាល់របស់ក្រុមហ៊ុនបានផងដែរ។ ការចុះត្រួតពិនិត្យ និងតាមដានដល់ទីកន្លែងរបស់ក្រុមហ៊ុននេះ គឺដើម្បីតាមដានលើប្រតិបត្តិការ និងការអនុវត្តលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។

ទន្ទឹមនឹងនេះ និយ័តករមូលបត្រកម្ពុជាអាចអន្តរាគមន៍គ្រប់ពេលវេលា ឬអាចបញ្ជាឱ្យក្រុមហ៊ុនផ្តល់ព័ត៌មានរបាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗតាមការចាំបាច់ដើម្បីធ្វើការត្រួតពិនិត្យពីដំណើរការនៃការវិនិយោគរបស់តួអង្គក្នុងវិស័យមូលបត្រឱ្យមានភាពល្អប្រសើរ ក៏ដូចជាការការពារផលប្រយោជន៍របស់វិនិយោគិននៅក្នុងវិស័យមូលបត្រ។ ចំពោះការត្រួតពិនិត្យ និងអន្តរាគមន៍គ្រប់ពេលវេលានេះ គឺដើម្បីធានាឱ្យបានទីផ្សារមួយដែលមានតម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់សម្រាប់ទីផ្សារមូលបត្រ។ ក្នុងករណីដែលនិយ័តករមូលបត្រកម្ពុជា បានពិនិត្យឃើញថាតួអង្គដែលបានចូលរួមក្នុងទីផ្សារមូលបត្រមានការប្រព្រឹត្តល្មើសនោះ និយ័តករមូលបត្រកម្ពុជានឹងធ្វើការស៊ើបអង្កេត និងចាត់វិធានការដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**១.១.២. ការអភិវឌ្ឍវិស័យមូលបត្រ**

**១.១.២.១. ការបង្កើតច្បាប់ បទប្បញ្ញត្តិ**

នៅក្នុងគោលដៅដើម្បីធានាដល់ដំណើរការអភិវឌ្ឍរបស់ទីផ្សារមូលបត្រ តាមរយៈការគ្រប់គ្រង ត្រួតពិនិត្យ និងតាមដានតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងសណ្តាប់ធ្នាប់ល្អ និយ័តករមូលបត្រកម្ពុជា បានរៀបចំច្បាប់ និងបទប្បញ្ញត្តិជាបន្តបន្ទាប់ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងតាមដាន

តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ។ គិតត្រឹមឆ្នាំ២០២៣ និយ័តករមូលបត្រកម្ពុជាមានច្បាប់ចំនួន២ អនុក្រឹត្យចំនួន ៤ ប្រកាសចំនួន៧០ និងគោលការណ៍ណែនាំចំនួន២៤ សម្រាប់ធ្វើការគ្រប់គ្រង និងត្រួតពិនិត្យទៅលើតួអង្គដែលចូលរួមក្នុងវិស័យមូលបត្រ ក៏ដូចជាអាជីវកម្មទាំងអស់ក្នុងវិស័យមូលបត្រ។ ចំពោះច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន គឺជាច្បាប់គោលដែលបានកំណត់ពីសិទ្ធិអំណាចរបស់និយ័តករមូលបត្រកម្ពុជាក្នុងការគ្រប់គ្រង ត្រួតពិនិត្យ ការអភិវឌ្ឍវិស័យមូលបត្រ និងគ្រប់គ្រងលើដំណើរការទីផ្សារមូលបត្រ។ ការរៀបចំអនុម័តច្បាប់ និងបទប្បញ្ញត្តិនេះធ្វើឡើងក្នុងគោលបំណងដើម្បីធានាបន្ថែមដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងការអភិវឌ្ឍវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជាបាននឹងកំពុងរៀបចំសេចក្តីព្រាងប្រកាស គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដើម្បីសម្រួលដល់ការអនុវត្ត ក៏ដូចជាចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។ បន្ថែមពីនេះ និយ័តករមូលបត្រកម្ពុជាគឺចង់រក្សាបាននៅទំនុកចិត្តចំពោះសាធារណជនដែលមានគម្រោងដាក់ទុនវិនិយោគ ឬវិនិយោគិនដែលអាចទទួលបានសិទ្ធិការពារស្របច្បាប់ប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌។ ការអនុម័តច្បាប់ និងបទប្បញ្ញត្តិនេះ បានជំរុញឱ្យវិនិយោគិនដែលចូលរួមក្នុងទីផ្សារមូលបត្រកាន់តែមានទំនុកចិត្តក្នុងការវិនិយោគ ក៏ដូចជាជួយជំរុញឱ្យមានអ្នកចូលរួមក្នុងទីផ្សារមូលបត្រកាន់តែច្រើនឡើង ។

### ១.១.២.២. ការអប់រំ និងការបណ្តុះបណ្តាល

វិស័យមូលបត្រ គឺជាវិស័យហិរញ្ញវត្ថុមួយដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងអភិវឌ្ឍន៍ដល់សេដ្ឋកិច្ចជាតិឱ្យរីកចម្រើន។ ទីផ្សារមូលបត្រកម្ពុជា គឺពុំអាចអភិវឌ្ឍន៍ទៅបានឡើយបើពុំមានអ្នកចូលរួមក្នុងទីផ្សារជាក់ស្តែង ដូចជានិយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ វិនិយោគិន និងតួអង្គចូលរួមផ្សេងទៀត។ ដូច្នេះ និយ័តករមូលបត្រកម្ពុជាដែលជាអាជ្ញាធរគ្រប់គ្រងត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្របានយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការជំរុញ និងលើកកម្ពស់ការយល់ដឹងដល់សាធារណជនពាក់ព័ន្ធនឹងចំណេះដឹងស្តីពីវិស័យមូលបត្រតាមរយៈការអប់រំគឺមានការបោះពុម្ពផ្សាយជាសាធារណៈនូវច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្ត សន្ធានុក្រមគតិយុត្ត និងរៀបចំផ្សព្វផ្សាយនូវអត្ថបទអប់រំខ្លីៗដូចជា ពុទ្ធិមូលបត្រ ព្រឹត្តិបត្រមូលបត្រ ខ្លីៗអំពីមូលបត្រ និងប៉ុស្ដិ៍មូលបត្រ ព្រមទាំងមានរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ។ល។ បន្ថែមពីនេះ និយ័តករមូលបត្រកម្ពុជាបានផ្សព្វផ្សាយព្រមទាំងបញ្ជ្រាបការយល់ដឹងតាមរយៈការរៀបចំជាវគ្គបណ្តុះបណ្តាល សិក្ខាសាលាដោយផ្ទាល់ឬតាមប្រព័ន្ធអនឡាញ ការអនុញ្ញាតនិងទទួល

យកសិស្ស-និស្សិតមកចុះទស្សនកិច្ចសិក្សា និងកម្មសិក្សា ការតាំងពិពណ៌ផ្សារភាគហ៊ុនកម្ពុជាដែលប្រព្រឹត្តទៅរៀងរាល់១ឆ្នាំម្តង និងបានរៀបចំយុទ្ធនាការផ្សព្វផ្សាយជាច្រើនផ្សេងទៀត។

## ១.២. រចនាសម្ព័ន្ធថ្នាក់ដឹកនាំ និងរចនាសម្ព័ន្ធបច្ចេកទេស

យោងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែន អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សរសេរអក្សរកាត់ថា អ.ស.ហ. ត្រូវបានបង្កើតឡើង និងមានអង្គភាពក្រោមឱវាទដែលជាសេនា-ធិការរបស់អាជ្ញាធរចំនួន ៨ រួមមាន "អគ្គលេខាធិការដ្ឋាន និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខសង្គម និយ័តករបរធនបាលកិច្ច និយ័តករគណនេយ្យនិងសវនកម្ម និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងអង្គភាពសវនកម្មផ្ទៃក្នុង"[1] ។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារមានរចនាសម្ព័ន្ធគ្រប់គ្រងដែលមានប្រធាន ១ (មួយ) រូបសម្រាប់ធ្វើការគ្រប់គ្រង ត្រួតពិនិត្យ អភិវឌ្ឍន៍ និងដឹកនាំ វិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យមានភាពរីកចម្រើនជឿនលឿន។ ចំណែកឯនិយ័តករមូលបត្រកម្ពុជាដែលជាអង្គភាពមួយស្ថិតនៅក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក៏មាននូវរចនាសម្ព័ន្ធគ្រប់គ្រងដាច់ដោយឡែកមួយសម្រាប់ធ្វើការគ្រប់គ្រងការងារប្រចាំថ្ងៃ ក៏ដូចជាធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងដឹកនាំស្ថាប័ន ដែលមានអគ្គនាយក ១ (មួយ) រូបជាប្រធាន ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ១.២.១. រចនាសម្ព័ន្ធថ្នាក់ដឹកនាំ

#### ១.២.១.១. អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាស្ថាប័នមួយដែលមានឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួនដែលគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ នាពេលបច្ចុប្បន្ននេះ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ គឺជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុមិនមែនធនាគាររួមមាន "វិស័យធានារ៉ាប់រងនិងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម វិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន"[2]។ ចំពោះការប្រមូលផ្តុំវិស័យហិរញ្ញវត្ថុមិនមែនធនាគារនេះ គឺក្នុងគោលបំណងដើម្បីធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍនិងប្រើប្រាស់បច្ចេក-វិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានភាពរីកចម្រើន។ យោងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាជ្ញាធរសេវាហិរញ្ញវត្ថុ

[1] មាត្រា១១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២១

[2] មាត្រា១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២១

មិនមែនធនាគារ គឺជាស្ថាប័នមួយដែលមានតួនាទី និងភារកិច្ច ក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិ រៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារដាក់ជូនរាជរដ្ឋាភិបាល ព្រមទាំងកំណត់ការត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ពង្រឹងទំនុកចិត្តទីផ្សារ គាំពារវិនិយោគិន និងទប់ស្កាត់ឧក្រិដ្ឋកម្មហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការចាត់ឱ្យមានការស៊ើបអង្កេត ប្រមូលព័ត៌មានពីគ្រប់បុគ្គលស្ថាប័នពាក់ព័ន្ធ និងអាចចាត់វិធានការបង្កកទ្រព្យសម្បត្តិឬសាច់ប្រាក់ក្នុងគណនីធនាគាររបស់បុគ្គលពាក់ព័ន្ធក្នុងករណីសង្ស័យប្រព្រឹត្តអំពើល្មើសក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារដោយអនុវត្តស្របតាមច្បាប់ជាធរមាន រួមចំណែករក្សានិងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ជំរុញការអភិវឌ្ឍនវានុវត្តន៍ហិរញ្ញវត្ថុ។

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងមានសមាសភាពចំនួន ១៧រូប ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន និងមានសមាជិកផ្សេងទៀតដែលមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ចំពោះ "ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារមានសមាសភាពដូចខាងក្រោម"[3] ៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| ៣. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៤. តំណាងធនាគារជាតិនៃកម្ពុជា ១រូប | សមាជិក |
| ៥. តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ៦. តំណាងក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| ៧. តំណាងក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| ៨. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ៩. អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១០.អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១១.អគ្គនាយកនៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| ១២.អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ១៣.អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |

[3] មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២១

១៤.អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ សមាជិក

១៥.អ្នកជំនាញអព្យាក្រឹតដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣រូប សមាជិក។

**១.២.១.២. អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា**

តាមដំណើរការនៃការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជា ត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គនាយក ១ (មួយ) រូប មានឋានៈ និងបុព្វសិទ្ធិស្មើ រដ្ឋលេខាធិការ នឹងត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ត្រូវតែជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព លក្ខណសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬច្រើនផ្នែក ដូចជាពាណិជ្ជកម្ម គ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងជំនាញផ្សេងទៀតទៅតាមតម្រូវការជាក់ស្តែង។ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា "មានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ អនុរដ្ឋលេខាធិការ"[4]។ បន្ថែមពីនេះ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ក៏អាចមានអ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេសក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រផងដែរ។ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា មានសិទ្ធិពេញលេញក្នុងការបំពេញការងារប្រចាំថ្ងៃក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រ ដោយអនុលោមតាមបញ្ញត្តិច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន នៅក្នុងដំណើរការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រឱ្យមានប្រសិទ្ធភាព របៀបរៀបរយ និងសណ្តាប់ធ្នាប់ ក៏ដូចជាក្នុងកិច្ចគាំពារវិនិយោគិននៅក្នុងវិស័យមូលបត្រ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា មានមុខងារ និងភារកិច្ចក្នុងការគ្រប់គ្រងស្ថាប័ន តួអង្គដែលបានចូលរួម និងផលិតផលដែលជាមូលបត្រដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា។ ចំពោះការគ្រប់គ្រងលើស្ថាប័នសាមី អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា មានតួនាទីគ្រប់គ្រងការងារប្រចាំថ្ងៃរបស់និយ័តករ ដូចជារៀបចំច្បាប់ និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងវិស័យមូលបត្រ គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញរបស់និយ័តករ រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ-អន្តរជាតិដើម្បីជួយជំរុញវិស័យមូលបត្រឱ្យរីកចម្រើន ការត្រួតពិនិត្យទីផ្សារមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមុខងារផ្សេងទៀតដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យមូលបត្រ។

[4] មាត្រា៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ឆ្នាំ២០០៨

ដោយឡែកសម្រាប់ការគ្រប់គ្រងលើតួអង្គដែលបានចូលរួម និងប្រតិបត្តិការអាជីវកម្មនៅក្នុងវិស័យមូលបត្រ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា មានមុខងារក្នុងការពិនិត្យទម្រង់ពាក្យស្នើសុំ សំណុំឯកសារ ឯកសារផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងទៀត ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។ បន្ថែមពីនេះ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាមានសិទ្ធិអំណាចក្នុងការពង្រឹងការអនុវត្តច្បាប់លើតួអង្គដែលបានចូលរួមក្នុងវិស័យមូល-បត្រ ដោយចាត់វិធានការពង្រឹងការអនុវត្តច្បាប់ស្របនឹងករណីដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ និងអ្នកដែលចូលរួមក្នុងទីផ្សារមូលបត្របានប្រព្រឹត្តអំពើល្មើស ឬបទល្មើស នឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ក្នុងករណីអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា បានពិនិត្យ និងមានមូលហេតុត្រឹមត្រូវនឹងជឿជាក់ថាមានប្រព្រឹត្តល្មើសទៅនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាអាចសម្រេចឱ្យបុគ្គលិករបស់ខ្លួនស៊ើបអង្កេតលើក្រុមហ៊ុន ឬបុគ្គលសង្ស័យ ដើម្បីប្រមូលភស្តុតាងពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតដើម្បីចាត់វិធានការស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ ឬបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាក្នុងករណីជាបទល្មើសព្រហ្មទណ្ឌ ដើម្បីចោទប្រកាន់ពីបទល្មើសបន្ត។

### ១.២.២. រចនាសម្ព័ន្ធបច្ចេកទេស

#### ១.២.២.១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

តាមដំណើរការអនុវត្តការងារប្រចាំថ្ងៃរបស់និយ័តករមូលបត្រកម្ពុជា នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ គឺជាសេនាធិការ និងជានាយកដ្ឋានជំនាញមួយក្នុងចំណោមនាយកដ្ឋានទាំង ៦ របស់និយ័តករមូលបត្រកម្ពុជាដែលមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ រៀបចំផែនការ និងថវិការបស់និយ័តករមូលបត្រកម្ពុជា រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃនិយ័តករមូលបត្រកម្ពុជា ផ្គត់ផ្គង់ និងជួសជុលសម្ភារៈបរិក្ខារការិយាល័យ ព្រមទាំងគ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រផ្ទៃក្នុងដើម្បីគ្រប់គ្រង និងធានាឱ្យមានប្រសិទ្ធភាពចំពោះការរៀបចំ និងការប្រព្រឹត្តទៅទាំងអស់របស់ស្ថាប័ននិយ័តករមូលបត្រកម្ពុជា ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ។ ក្រៅពីនេះ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុត្រូវអនុវត្តការងារផ្សេងៗទៀតទៅតាមការចាំបាច់ដែលប្រគល់ជូនដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាសម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ ដើម្បីធានាបានប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុ-ប្រធាននាយកដ្ឋានជាជំនួយការទៅតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្ន ដើម្បីធានាប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានការិយាល័យចំណុះចំនួន ៤ សម្រាប់

ជួយបំពេញការងារ និងអនុវត្តការងារជាប្រចាំរបស់នាយកដ្ឋាន រួមមាន ការិយាល័យរដ្ឋបាល និងបុគ្គលិក ការិយាល័យ គណនេយ្យ និងហិរញ្ញវត្ថុ ការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា និងការិយាល័យផែនការថវិកា។ សម្រាប់ការិយាល័យនីមួយៗ ត្រូវមានប្រធានការិយាល័យ ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យ ព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារជាប្រចាំថ្ងៃ។ បន្ថែមពីនេះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក៏មានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

**១.២.២.២. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានតួនាទី និងភារកិច្ច សិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍវិស័យមូលបត្រ និងជំរុញឱ្យមានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ តាមរយៈការរៀបចំរចនាសម្ព័ន្ធច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ ព្រមទាំងការសិក្សាវាយតម្លៃ និងការផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗមុននឹងអនុញ្ញាតឱ្យធ្វើការបោះផ្សាយ ឬដាក់ឱ្យជួញដូរលើទីផ្សារមូលបត្រកម្ពុជា ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ។ ក្រៅពីតួនាទី និងភារកិច្ចក្នុងការសិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រ នាយកដ្ឋានក៏មានតួនាទី និងភារកិច្ចក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ ពាក់ព័ន្ធនឹងចំណេះដឹងផ្នែកមូលបត្រឱ្យកាន់តែទូលំទូលាយដើម្បីកៀរគរសាធារណជន និងអ្នកចូលរួមក្នុងវិស័យមូលបត្រឱ្យកាន់តែច្រើនមកចូលរួមក្នុងទីផ្សារ ក៏ដូចជាដើម្បីបញ្ជ្រាបការយល់ដឹងជូនដល់សាធារណជន និងអ្នកចូលរួមផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ក៏ជាសេនាធិការរបស់និយ័តករមូលបត្រកម្ពុជាក្នុងការធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ សមាគម អង្គការអន្តរជាតិនានា និងក្នុងពិភពលោក ក្នុងការស្វែងរកជំនួយកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូអភិវឌ្ឍន៍ ព្រមទាំងការស្វែងរកជំនួយ ឬហិរញ្ញប្បទានផ្សេងៗពីដៃគូអភិវឌ្ឍន៍ដើម្បីយកមកធ្វើការអភិវឌ្ឍវិស័យមូលបត្រឱ្យកាន់តែមានភាពរីកចម្រើន តាមរយៈការចុះកិច្ចព្រមព្រៀង ឬចុះអនុស្សារណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជាជាមួយដៃគូអភិវឌ្ឍន៍ទាំងនោះ។ បន្ថែមពីនេះ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ត្រូវអនុវត្តការងារផ្សេងៗទៀតតាមការចាំបាច់ដែលប្រគល់ជូនដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាសម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ ដើម្បីធានានូវប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ត្រូវគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្ននេះ ដើម្បីធានាបានប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានការិយាល័យចំណុះចំនួន ៣ រួមមានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ និងការិយាល័យទំនាក់ទំនងអន្តរជាតិ។ សម្រាប់ការិយាល័យនីមួយៗ ត្រូវមានប្រធានការិយាល័យ ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យ ព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារប្រចាំថ្ងៃផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

### **១.២.២.៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

អនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានតួនាទី និងភារកិច្ច ពិនិត្យ និងរៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា ក្នុងការគ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រ និងដើម្បីផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។ នាយកដ្ឋានមានតួនាទី និងភារកិច្ច ក្នុងការរៀបចំលក្ខខណ្ឌតម្រូវ និងយុទ្ធសាស្ត្រជាប្រចាំ ទាក់ទងនឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍរបស់អភិបាលកិច្ចសាជីវកម្មឱ្យមានភាពល្អប្រសើរសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការត្រួតពិនិត្យ និងផ្តល់យោបល់ចំពោះពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានផ្សេងៗដែលមានកំណត់តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បន្ថែមលើតួនាទី និងភារកិច្ចត្រួតពិនិត្យលើឯកសារផ្តល់ព័ត៌មាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រក៏អាចចុះត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់ ដើម្បីធានាបានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពដល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្នុងករណីដែលនាយកដ្ឋានបានពិនិត្យរកឃើញថា មានករណីសង្ស័យ ឬមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ នាយកដ្ឋាននឹងបញ្ជូនករណីសង្ស័យ ឬករណីមានការប្រព្រឹត្តល្មើសទៅនាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា ដើម្បីធ្វើការស៊ើបអង្កេតបន្ត និង/ឬ ដើម្បីចាត់វិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

បន្ថែមពីនេះ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ក៏ត្រូវអនុវត្តការងារផ្សេងៗទៀតទៅតាមការចាំបាច់ដែលប្រគល់ជូនដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាសម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ ដើម្បីធានាប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ត្រូវគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្នដើម្បីធានាបានប្រសិទ្ធភាពការអនុវត្តការងាររបស់នាយកដ្ឋាន នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានការិយាល័យចំណុះចំនួន ៤ រួមមាន ការិយាល័យបោះផ្សាយមូលបត្រ និងឯកសារផ្តល់ព័ត៌មាន ការិយាល័យអភិបាលកិច្ចសាជីវកម្ម ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ និងការិយាល័យគ្រប់គ្រងព័ត៌មានសាជីវកម្ម។ សម្រាប់ការិយាល័យនីមួយៗ ត្រូវមានប្រធានការិយាល័យចំនួន ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យ ព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារប្រចាំថ្ងៃផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

**១.២.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ មានតួនាទី និងភារកិច្ច ធ្វើការពិនិត្យ និងរៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា ដើម្បីផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំសម្រាប់ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការជាប្រតិបត្តិករទាំង ៣ របស់ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា សរសេរអក្សរកាត់ថា ផមក រួមមាន ប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ។ បន្ថែមពីការពិនិត្យ និងរៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា ដើម្បីផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំនាយកដ្ឋានមានតួនាទី និងភារកិច្ចសំខាន់មួយទៀតគឺត្រួតពិនិត្យ និងតាមដានលើឯកសារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់និយ័តករមូលបត្រកម្ពុជា លើប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទាំង ៣ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាតាមរយៈការពិនិត្យលើឯកសារផ្តល់ព័ត៌មានដែលផ្តល់ដោយប្រតិបត្តិកររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាជាប្រចាំ។ បន្ថែមលើតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យលើឯកសារផ្តល់ព័ត៌មានដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ក៏អាចចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ដើម្បីធានាបានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពក្នុងទីផ្សារ។ ក្នុងករណីដែលនាយកដ្ឋានបានពិនិត្យឃើញថា មានករណីសង្ស័យ ឬមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិកររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នាយកដ្ឋាននឹងបញ្ជូនករណីសង្ស័យ ឬករណីមានការប្រព្រឹត្តល្មើសទៅនាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា ដើម្បីស៊ើបអង្កេតបន្ត និង/ឬ ដើម្បីចាត់វិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បន្ថែមពីនេះ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ត្រូវអនុវត្តការងារផ្សេងៗទៀតតាមការចាំបាច់ដែលប្រគល់ជូនដោយអគ្គ-នាយកនៃនិយ័តករមូលបត្រកម្ពុជាសម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ដើម្បីធានាប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ត្រូវគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្ននេះ ដើម្បីធានាបានប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានការិយាល័យចំណុះចំនួន ៣ រួមមានការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ ការិយាល័យត្រួតពិនិត្យប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ។ សម្រាប់ការិយាល័យនីមួយៗ ត្រូវមានប្រធានការិយាល័យ ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យ ព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារប្រចាំថ្ងៃផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

### ១.២.២.៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

អនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានតួនាទី និងភារកិច្ច ក្នុងការរៀបចំបទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដែលបានដាក់ពាក្យស្នើសុំពីអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាដើម្បីធ្វើការពិនិត្យ និងទទួលការអនុញ្ញាតមុនចាប់ផ្តើមប្រកបអាជីវកម្ម។ នាយកដ្ឋានមានតួនាទី ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាបណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ។ ក្រៅពីនេះនាយកដ្ឋានអាចត្រួតពិនិត្យ និងតាមដានជាប្រចាំដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់និយ័តករមូលបត្រកម្ពុជា លើប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ តាមរយៈការពិនិត្យលើឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុន និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ។ ការចុះត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់ ដើម្បីពិនិត្យ និង

តាមដាន ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃនៅក្នុងទីផ្សារ ដើម្បីធានាឱ្យបានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពក្នុងទីផ្សារ។ ក្នុងករណីដែលនាយកដ្ឋានបានពិនិត្យរកឃើញថាមានករណីសង្ស័យ ឬមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹង ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នឹងបញ្ជូនករណីសង្ស័យ ឬមានការប្រព្រឹត្តល្មើសទៅនាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា ដើម្បីស៊ើបអង្កេតបន្ត និង/ឬ ដើម្បីចាត់វិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បន្ថែមពីនេះ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ត្រូវអនុវត្តការងារផ្សេងៗទៀតទៅតាមការចាំបាច់ដែលបានប្រគល់ជូនដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជាសម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ ដើម្បីធានាប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ត្រូវគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្ននេះ ដើម្បីធានាបានប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានការិយាល័យចំណុះចំនួន ៤ រួមមានការិយាល័យសម្របសម្រួល និងអាជ្ញាបណ្ណ ការិយាល័យត្រួតពិនិត្យលើឯកសារ ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង និងការិយាល័យគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម និងឧបករណ៍និស្សន្ទ។ សម្រាប់ការិយាល័យនីមួយៗ ត្រូវមានប្រធានការិយាល័យ ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារប្រចាំថ្ងៃផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

#### **១.២.២.៦. នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្ត មានតួនាទី និងភារកិច្ច ក្នុងការរៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីធានាឱ្យបានសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងទីផ្សារមូលបត្រ ដើម្បីជួយដល់ការអភិវឌ្ឍក្នុងវិស័យមូលបត្រ ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ។ បន្ថែមពីនេះ នាយកដ្ឋានអាចពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដែលបានដាក់ពាក្យស្នើសុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ និយ័តករមូលបត្រ

កម្ពុជា។ តួនាទីក្នុងការទទួលពាក្យបណ្ដឹង និងការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ជូនវិយោគិនក្នុងវិស័យមូលបត្រ។ ការស៊ើបអង្កេតអំពើល្មើស និងបទល្មើស ពាក់ព័ន្ធនឹងវិស័យមូលបត្រដែលមានដូចជា ប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី និងករណីផ្សេងទៀតដែលកើតមានឡើងក្នុងទីផ្សារដំបូង និងទីផ្សារបន្ទាប់។ បំពេញតួនាទីក្នុងការបញ្ជូនពាក្យបណ្ដឹងទៅតុលាការ (ក្នុងករណីមានការស្នើសុំពីភាគីវិវាទ) និង/ឬរៀបចំបញ្ជូនសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសទៅតុលាការដើម្បីបន្តនីតិវិធី។ ការពិនិត្យ និងផ្ដល់យោបល់ ដើម្បីចាត់វិធានការផាកពិន័យអន្តរការណ៍លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាក្នុងវិស័យមូលបត្រ ទប់ស្កាត់ និងបង្ក្រាបការជួញដូរផ្ទៃក្នុង ប្រតិបត្តិការបោះផ្សាយលក់ ឬជួញដូរមូលបត្រ ដែលល្មើសច្បាប់ ឬមិនប្រក្រតី រួមទាំងព័ត៌មានចចាមអារ៉ាមនានា ដែលអាចប៉ះពាល់ដល់ស្ថេរភាពទីផ្សារ។ រៀបចំផ្សព្វផ្សាយករណីប្រព្រឹត្តល្មើសផ្សេងៗពាក់ព័ន្ធនឹងវិស័យមូលបត្រ ព្រមទាំងចងក្រងច្បាប់ និងរក្សាទិន្នន័យពាក់ព័ន្ធនឹងករណីប្រព្រឹត្តល្មើស។ បន្ថែមពីនេះ នាយកដ្ឋានកិច្ចការគតិយុត្តត្រូវអនុវត្តការងារផ្សេងៗទៀតតាមការចាំបាច់ដែលប្រគល់ជូនដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា សម្រាប់បន្ថែមលើមុខងារ និងតួនាទីដែលមានស្រាប់ ដើម្បីធានាបានប្រសិទ្ធភាពការងាររបស់និយ័តករមូលបត្រកម្ពុជា។

នាយកដ្ឋានកិច្ចការគតិយុត្តត្រូវបានគ្រប់គ្រង និងដឹកនាំដោយប្រធាននាយកដ្ឋាន ១ រូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃ។ នាពេលបច្ចុប្បន្នដើម្បីធានាប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន នាយកដ្ឋានកិច្ចការគតិយុត្ត មានការិយាល័យចំណុះចំនួន ៣ រួមមានការិយាល័យពង្រឹងការអនុវត្តច្បាប់និងនីតិកម្ម ការិយាល័យទទួលពាក្យបណ្ដឹង និងដោះស្រាយវិវាទ និងការិយាល័យស៊ើបអង្កេត។ សម្រាប់ការិយាល័យនីមួយៗត្រូវមានប្រធានការិយាល័យ ១ រូប សម្រាប់គ្រប់គ្រង និងដឹកនាំការងារក្នុងការិយាល័យ ព្រមទាំងមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់ក្នុងការបំពេញ និងអនុវត្តការងារប្រចាំថ្ងៃផងដែរ។ បន្ថែមពីនេះ នាយកដ្ឋានកិច្ចការគតិយុត្ត មានមន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ដើម្បីបំពេញការងារជាប្រចាំក្នុងការិយាល័យ។

# ជំពូកទី២
# យន្តការដោះស្រាយវិវាទ និងបង្ក្រាប
# ការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

# ជំពូកទី២

# យន្តការដោះស្រាយវិវាទ និងបង្ក្រាបការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

## ២.១.ការទទួលពាក្យបណ្ដឹង និងការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ

យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគោលការណ៍របស់អង្គការគណៈកម្មការមូលបត្រអន្តរជាតិ (International Organization of Securities Commission-IOSCO) និងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community Blueprint) និយ័តករមូលបត្រកម្ពុជាបានបង្កើតឱ្យមានមជ្ឈមណ្ឌលដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងជាមជ្ឈមណ្ឌលទទួលបន្ទុកដោះស្រាយវិវាទនៃនាយកដ្ឋានកិច្ចការគតិយុត្ត ដែលមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចគាំពារដល់វិនិយោគិន តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ និងទីផ្សារមូលបត្រតាមរយៈការទទួលពាក្យបណ្ដឹងពីអ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដោះស្រាយវិវាទក្នុងទិសដៅរក្សានូវទំនុកចិត្ត និងកិច្ចគាំពារអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ជាពិសេសវិនិយោគិនសាធារណៈ។

អនុលោមតាមប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ វិវាទ ឬវិវាទក្នុងវិស័យមូលបត្រ សំដៅដល់គ្រប់ការទាមទារ ជម្លោះ ឬទំនាស់ពាក់ព័ន្ធនឹងមូលបត្រ ឬផ្ដល់សេវាក្នុងវិស័យមូលបត្រ។ រាល់វិវាទពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មមូលបត្រ "ភាគីជម្លោះអាចដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ចដូចជា មជ្ឈត្តកម្ម ឬតុលាការ ឬនិយ័តករមូលបត្រកម្ពុជា ដែលជាអាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យមូលបត្រ ដើម្បីដោះស្រាយវិវាទលើកលែងករណីរឿងព្រហ្មទណ្ឌ"[5] ។

### ២.១.១. ពាក្យបណ្ដឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ

#### ២.១.១.១. ការដាក់ និងទទួលពាក្យបណ្ដឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ

អនុលោមតាមប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ភាគីជម្លោះអាចដាក់ពាក្យបណ្ដឹងសុំការផ្សះផ្សា និងពាក្យបណ្ដឹងសុំការដោះស្រាយវិវាទ ជូននិយ័តករមូលបត្រកម្ពុជាតាមទម្រង់ដែលមានកំណត់ដោយនិយ័តករមូលបត្រកម្ពុជា។ សម្រាប់ការដាក់ពាក្យបណ្ដឹងនេះ ភាគីជម្លោះអាចដាក់ពាក្យបណ្ដឹងជូននិយ័តករមូលបត្រកម្ពុជាដោយផ្ទាល់ ឬអាចដាក់ពាក្យបណ្ដឹងតាមរយៈអ្នកតំណាងរបស់ខ្លួនស្របតាមបញ្ញត្តិនៃច្បាប់ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះការដាក់ពាក្យបណ្ដឹងសុំការផ្សះផ្សា "ភាគីជម្លោះត្រូវបំពេញព័ត៌មានទៅតាមទម្រង់ពាក្យបណ្ដឹងសុំការផ្សះផ្សាដូចមានកំណត់ដោយនិយ័តករមូលបត្រកម្ពុជា ដែលមានជាអាទិ៍"[6]៖

[5] មាត្រា៤៣ នៃច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ឆ្នាំ២០០៧

[6] ទម្រង់ពាក្យបណ្ដឹងសុំការផ្សះផ្សារបស់និយ័តករមូលបត្រកម្ពុជា

១-ព័ត៌មានរបស់ភាគីសុំការផ្សះផ្សា សម្រាប់រូបវន្តបុគ្គលត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដូចជា៖ គោត្តនាម និងនាម អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ មុខរបររបស់គូភាគីជម្លោះ) ព្រមទាំងលេខទូរសព្ទ អ៊ីមែល សម្រាប់ទំនាក់ទំនង។ ដោយឡែក សម្រាប់នីតិបុគ្គលដែលជាភាគីសុំការផ្សះផ្សាត្រូវបំពេញព័ត៌មានមួយចំនួនដូចជា នាមករណ៍ លេខចុះបញ្ជីក្រសួងពាណិជ្ជកម្ម កាលបរិច្ឆេទចុះបញ្ជី លេខអាជ្ញាបណ្ណធ្វើអាជីវកម្ម (ប្រសិនបើមាន) កាលបរិច្ឆេទចេញដោយក្រសួង-ស្ថាប័ន ព្រមទាំងអាសយដ្ឋាន លេខទូរសព្ទ អ៊ីមែល សម្រាប់ទំនាក់ទំនង។ បន្ថែមពីនេះ សម្រាប់នីតិបុគ្គល ក៏អាចធ្វើឡើងតាមរយៈអ្នកតំណាងផងដែរប្រសិនបើមាន។

២-ព័ត៌មានរបស់ភាគីជម្លោះម្ខាងទៀត គឺត្រូវបំពេញដូចគ្នាទៅនឹងព័ត៌មានរបស់ភាគីស្នើសុំការផ្សះផ្សាដូចមានរៀបរាប់ក្នុងចំណុចទី១ ខាងលើ។

៣-ព័ត៌មានពាក់ព័ន្ធនឹងវិវាទ ដែលតម្រូវឱ្យបំពេញនូវកម្មវត្ថុនៃបណ្តឹងដែលភាគីបានទាមទារ និងសេចក្តីសង្ខេបពាក់ព័ន្ធនឹងវិវាទរបស់ភាគី។

៤-ភាគីជម្លោះត្រូវបង្ហាញយន្តការដែលធ្លាប់បាន ឬកំពុងប្រើប្រាស់សម្រាប់ការដោះស្រាយវិវាទ ដែលបានធ្វើនាពេលកន្លងមកមានដូចជា កាលបរិច្ឆេទនៃការចរចា លទ្ធផលនៃការចរចា (ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធនឹងការចរចាប្រសិនបើមាន) ឬធ្លាប់បានដាក់ពាក្យបណ្តឹងទៅ មជ្ឈត្តការ(បញ្ជាក់ពីកាលបរិច្ឆេទ និងភ្ជាប់មកនូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មថតចម្លង) ឬតុលាការ(បញ្ជាក់ពីកាលបរិច្ឆេទ និងភ្ជាប់មកនូវពាក្យបណ្តឹងនិងបង្កាន់ដៃបង់ប្រាក់ប្រដាប់ក្តីថតចម្លង) ជាដើម។

៥-ឯកសារភ្ជាប់ផ្សេងទៀតដែលតម្រូវដោយនិយ័តករមូលបត្រកម្ពុជា មានជាអាទិ៍ អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនថតចម្លង កិច្ចព្រមព្រៀងអតិថិជន/កិច្ចព្រមព្រៀងផ្តល់សេវាពាក់ព័ន្ធ លិខិតផ្ទេរសិទ្ធិសម្រាប់អ្នកតំណាង(ប្រសិនបើមាន) សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម/ពាក្យបណ្តឹងនៅតុលាការ និងបង្កាន់ដៃបង់ប្រាក់ប្រដាប់ក្តី (ប្រសិនបើមាន) និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ការដាក់ពាក្យបណ្តឹងសុំការដោះស្រាយវិវាទ "ភាគីជម្លោះត្រូវបំពេញព័ត៌មានទៅតាមទម្រង់ពាក្យបណ្តឹងសុំការដោះស្រាយវិវាទដែលមានកំណត់ដោយនិយ័តករមូលបត្រកម្ពុជា មានជាអាទិ៍"[7]៖

១-ព័ត៌មានរបស់ភាគីសុំការដោះស្រាយវិវាទ សម្រាប់រូបវន្តបុគ្គលត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដូចជា៖ គោត្តនាម និងនាម អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ មុខរបររបស់គូភាគីជម្លោះ) ព្រមទាំងលេខទូរសព្ទ អ៊ីមែល សម្រាប់ទំនាក់ទំនង។ ដោយឡែកសម្រាប់នីតិបុគ្គលដែលជាភាគី

[7] ទម្រង់ពាក្យបណ្តឹងសុំការផ្សះផ្សារបស់និយ័តករមូលបត្រកម្ពុជា

សុំការដោះស្រាយវិវាទ ត្រូវបំពេញព័ត៌មានមួយចំនួនដូចជា នាមករណ៍ លេខចុះបញ្ជីក្រសួងពាណិជ្ជកម្ម កាលបរិច្ឆេទចុះបញ្ជី លេខអាជ្ញាបណ្ណធ្វើអាជីវកម្ម (ប្រសិនបើមាន) កាលបរិច្ឆេទដែលចេញដោយក្រសួង-ស្ថាប័ន ព្រមទាំងអាសយដ្ឋាន លេខទូរសព្ទ អ៊ីមែល សម្រាប់ធ្វើការទំនាក់ទំនង។ បន្ថែមពីនេះ សម្រាប់នីតិបុគ្គល ក៏អាចធ្វើឡើងតាមរយៈអ្នកតំណាងផងដែរ(ប្រសិនបើមាន)។

២-ព័ត៌មានរបស់ភាគីជម្លោះម្ខាងទៀត គឺត្រូវបំពេញដូចគ្នានឹងព័ត៌មានរបស់ភាគីស្នើសុំការដោះស្រាយវិវាទដូចដែលបានរៀបរាប់នៅក្នុងចំណុចទី១ ខាងលើ។

៣-ព័ត៌មានពាក់ព័ន្ធនឹងវិវាទ ដែលតម្រូវឱ្យភាគីជម្លោះបំពេញនូវកម្មវត្ថុនៃការទាមទារ តម្លៃកម្មវត្ថុនៃការទាមទារ និងយន្តការធ្លាប់បាន ឬកំពុងដាក់ពាក្យបណ្តឹងទៅមជ្ឈត្តការ(បញ្ជាក់ពីកាលបរិច្ឆេទ និងភ្ជាប់មកនូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មចតចម្លង) ឬតុលាការ(បញ្ជាក់ពីកាលបរិច្ឆេទ និងភ្ជាប់មកនូវពាក្យបណ្តឹងនិងបង្កាន់ដៃបង់ប្រាក់ប្រដាប់ក្តីថតចម្លង) កាលបរិច្ឆេទនៃកំណត់ហេតុមិនសះជាលើវិវាទដែលចេញដោយអ្នកផ្សះផ្សាវិវាទរបស់និយ័តករមូលបត្រកម្ពុជា។

៤-ឯកសារភ្ជាប់ផ្សេងទៀតដែលត្រូវភ្ជាប់ជូននិយ័តករមូលបត្រកម្ពុជា មានជាអាទិ៍ កំណត់ហេតុផ្សះផ្សាមិនសះជា លិខិតផ្ទេរសិទ្ធិសម្រាប់អ្នកតំណាង(ប្រសិនបើមាន) សេចក្តីជូនដំណឹងពីមជ្ឈត្តកម្ម/ពាក្យបណ្តឹងនៅតុលាការ និងបង្កាន់ដៃបង់ប្រាក់ប្រដាប់ក្តី (ប្រសិនបើមាន) និងឯកសារផ្សេងទៀត។

បន្ទាប់ពីភាគីជម្លោះបានបំពេញព័ត៌មានក្នុងទម្រង់ដាក់ពាក្យបណ្តឹងសុំការផ្សះផ្សា និងពាក្យបណ្តឹងសុំការដោះស្រាយវិវាទរួចរាល់ ភាគីជម្លោះអាចធ្វើការដាក់ពាក្យបណ្តឹងនោះមកនិយ័តករមូលបត្រកម្ពុជាដើម្បីពិនិត្យ និងចាប់ផ្តើមចំណាត់ការលើពាក្យបណ្តឹង។

### ២.១.១.២. ចំណាត់ការលើពាក្យបណ្តឹងសុំការផ្សះផ្សា និងការដោះស្រាយវិវាទ

បន្ទាប់ពីបានទទួលពាក្យបណ្តឹងសុំការផ្សះផ្សា និងពាក្យបណ្តឹងសុំការដោះស្រាយវិវាទ ដែលភាគីជម្លោះបានដាក់ជូននិយ័តករមូលបត្រកម្ពុជាតាមរយៈនាយកដ្ឋានកិច្ចការគតិយុត្តសម្រាប់ករណីបណ្តឹងសុំការផ្សះផ្សា និងតាមរយៈការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទនៃនាយកដ្ឋានកិច្ចការគតិយុត្តសម្រាប់ករណីបណ្តឹងសុំការដោះស្រាយវិវាទរួចហើយ និយ័តករមូលបត្រកម្ពុជា និងចាប់ផ្តើមចំណាត់ការលើពាក្យបណ្តឹងទៅតាមនីតិវិធីដូចមានកំណត់ក្នុងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រ។

ករណីពាក្យបណ្តឹងសុំការផ្សះផ្សា បន្ទាប់ពីភាគីជម្លោះបានដាក់ពាក្យបណ្តឹងជូននិយ័តករមូលបត្រកម្ពុជារួចហើយ នាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា នឹងបន្តចំណាត់ការលើពាក្យបណ្តឹងនោះ

ដោយពិនិត្យលើពាក្យបណ្តឹង និងព័ត៌មានដែលភាគីជម្លោះបានបំពេញនៅក្នុងទម្រង់នៃពាក្យបណ្តឹងដែលបានកំណត់ដោយនិយ័តករមូលបត្រកម្ពុជា រួមមាន ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីជម្លោះ កម្មវត្ថុនៃបណ្តឹង និងខ្លឹមសារនៃការទាមទារ អង្គហេតុ ព្រមទាំងមានភ្ជាប់ឯកសារពាក់ព័ន្ធផ្សេងទៀត។ ការបន្តចំណាត់ការលើពាក្យបណ្តឹងនេះ មន្ត្រីជំនាញនៃនាយកដ្ឋានកិច្ចការគតិយុត្តអាចស្នើឱ្យភាគីជម្លោះផ្តល់រាល់ឯកសារ ឬព័ត៌មានបន្ថែម និងភ្ជាប់មកជាមួយឯកសារមួយចំនួនក្នុងករណីចាំបាច់បានផងដែរ។ ក្នុងករណីឯកសារភ្ជាប់ដែលភាគីជម្លោះបានផ្តល់ជូននិយ័តករមូលបត្រកម្ពុជាជាភាសាបរទេស (ឯកសារដើម) ភាគីជម្លោះត្រូវបកប្រែជាភាសាខ្មែរជាមុនមុននឹងដាក់ជូនមកនិយ័តករមូលបត្រកម្ពុជា។ បន្ថែមពីនេះ "ក្នុងករណីដែលព័ត៌មាននៅក្នុងពាក្យបណ្តឹងមិនគ្រប់-គ្រាន់ ឬមិនទាន់សមស្រប នាយកដ្ឋានកិច្ចការគតិយុត្ត អាចបង្គាប់ឱ្យភាគីជម្លោះធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងពាក្យបណ្តឹងក្នុងរយៈពេល ៧ ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃអ្នកដាក់ពាក្យបណ្តឹងទទួលបានការជូនដំណឹងឱ្យកែតម្រូវនោះ"[8] ឬធ្វើការទំនាក់ទំនងទៅគ្រប់ភាគីជម្លោះដើម្បីឱ្យភាគីជម្លោះចុះកិច្ចព្រមព្រៀងផ្សះផ្សាទៅតាមទម្រង់ដែលកំណត់ដោយនិយ័តករមូលបត្រកម្ពុជា។ នាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា ក៏អាចបដិសេធលើពាក្យបណ្តឹងផ្សះផ្សា ករណីកម្មវត្ថុនៃពាក្យបណ្តឹងមិនពាក់ព័ន្ធនឹងវិវាទក្នុងវិស័យមូលបត្រ ពាក្យបណ្តឹងមានព័ត៌មានមិនគ្រប់គ្រាន់ អ្នកប្តឹងគ្មានសមត្ថភាព ឬមិនមានផលប្រយោជន៍ក្នុងវិវាទ ពាក្យបណ្តឹងពាក់ព័ន្ធនឹងបទល្មើសពាក្យបណ្តឹងដែលកំពុង ឬត្រូវបានដោះស្រាយដោយមជ្ឈត្តការ ឬតុលាការ សិទ្ធិប្តឹងត្រូវបានរលត់ដោយផុតអាជ្ញា-យុកាល។ ក្នុងករណីដែលនាយកដ្ឋានកិច្ចការគតិយុត្តនៃនិយ័តករមូលបត្រកម្ពុជា ធ្វើការបដិសេធលើពាក្យបណ្តឹងសុំការផ្សះផ្សាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ត្រូវជូនដំណឹងដល់ភាគីជម្លោះដែលបានដាក់ពាក្យបណ្តឹង។

បន្ទាប់ពីបានបញ្ចប់ការពិនិត្យលើពាក្យបណ្តឹង អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជានឹងតែងតាំងអ្នកផ្សះផ្សាជាមន្ត្រីរបស់និយ័តករមូលបត្រកម្ពុជា ដើម្បីផ្សះផ្សាវិវាទក្នុងវិស័យមូលបត្រដែលមាន "សមាសភាព ១ (មួយ) រូប ឬច្រើនរូប ប៉ុន្តែមិនត្រូវលើសពី ៣ (បី) រូប តាមសំណើរបស់ប្រធានការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ"[9] ។ ទន្ទឹមនឹងនេះ អនុលោមតាមប្រការ១៤ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ សម្រាប់ករណីអ្នកផ្សះផ្សាជា ឬធ្លាប់ជាសហព័ទ្ធនៃភាគីជម្លោះ ជាញាតិលោហិតរហូតដល់ថ្នាក់ទី៤ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីជម្លោះណាមួយ ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីជម្លោះជាបុគ្គលដែលមានផលប្រយោជន៍ក្នុងវិវាទ ធ្លាប់ជាសាក្សី ឬជាអ្នកតំណាង ឬជាអ្នកជំនាញផ្តល់ប្រឹក្សាឱ្យភាគីជម្លោះ ឬស្ថិតក្នុងស្ថានភាពណាមួយដែលលេចចេញនូវភាពលំអៀង ឬទំនាស់ផលប្រយោជន៍ អ្នកផ្សះផ្សានឹងមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តតួនាទីជាអ្នកផ្សះផ្សាវិវាទក្នុងវិស័យមូលបត្រឡើយ ហើយក្នុងករណីដែលបុគ្គលដែលត្រូវ

[8] ប្រការ៥ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

[9] ប្រការ១១ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

ចាត់តាំងនោះមានជាប់ពាក់ព័ន្ធនឹងវិវាទ ឬផលប្រយោជន៍ណាមួយនៃវិវាទ ត្រូវជូនដំណឹងជាបន្ទាន់មកអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា តាមរយៈការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ។ សម្រាប់បុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងវិវាទ ឬផលប្រយោជន៍ណាមួយពាក់ព័ន្ធនឹងវិវាទ និងត្រូវបានចាត់តាំងអ្នកផ្សះផ្សា ហើយមានតួនាទី និងភារកិច្ច ក្នុងការស្វែងយល់ពីចំណុចវិវាទតាមរយៈការសាកសួរភាគីជម្លោះ ការកំណត់នូវចំណុចវិវាទដើម្បីស្វែងរកវិធីសាស្ត្រសម្រាប់ការផ្សះផ្សា ផ្តល់ភាពងាយស្រួលដល់ភាគីជម្លោះក្នុងការចរចាប្រកបដោយសន្តិវិធី ព្រមទាំងបង្កើតជម្រើសផ្សេងៗដែលជាដំណោះស្រាយសម្រាប់ឱ្យភាគីជម្លោះពិចារណាដើម្បីសះជា។ បន្ថែមពីនេះ "អ្នកផ្សះផ្សា ត្រូវលើកទឹកចិត្ត និងជំរុញភាគីជម្លោះឈានទៅដល់ការព្រមព្រៀងគ្នាតាមដែលអាចធ្វើទៅបាន អនុវត្តមុខងារ និងភារកិច្ចដោយត្រឹមត្រូវស្រមតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននៃការផ្សះផ្សា"[10] អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងក្នុងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យមូលបត្រ។

បន្ទាប់ពីភាគីជម្លោះផ្សះផ្សាមិនសះជា ភាគីជម្លោះអាចដាក់ពាក្យសុំការដោះស្រាយវិវាទមកនិយ័តករមូលបត្រកម្ពុជាតាមរយៈការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទនៃនាយកដ្ឋានកិច្ចការគតិយុត្ត តាមទម្រង់ដែលមានកំណត់ដោយនិយ័តករមូលបត្រកម្ពុជា។ បន្ទាប់មកការិយាល័យទទួលពាក្យបណ្តឹង និងដោះ-ស្រាយវិវាទនឹងពិនិត្យពាក្យបណ្តឹង និងព័ត៌មានដែលភាគីជម្លោះបានបំពេញនៅក្នុងពាក្យបណ្តឹងដូចគ្នាទៅនឹងពាក្យបណ្តឹងសុំការផ្សះផ្សាផងដែរ មានជាអាទិ៍ ព័ត៌មានរបស់ភាគីសុំការដោះស្រាយវិវាទ ព័ត៌មានរបស់ភាគីជម្លោះម្ខាងទៀត ព័ត៌មានពាក់ព័ន្ធនឹងវិវាទ ព្រមទាំងឯកសារភ្ជាប់ផ្សេងទៀតដែលត្រូវភ្ជាប់ជូននិយ័តករមូលបត្រកម្ពុជា។ ពាក្យបណ្តឹងស្នើសុំការដោះស្រាយវិវាទ អាចនឹងត្រូវបានធ្វើការបដិសេធក្នុងករណីដែលការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទនៃនាយកដ្ឋានកិច្ចការគតិយុត្ត បានពិនិត្យពាក្យបណ្តឹងឃើញថា "អាជ្ញាយុកាលនៃបណ្តឹងដែលបានមកនិយ័តករមូលបត្រកម្ពុជាមានរយៈពេលលើសពី ៩០ (កៅសិប) ថ្ងៃគិតពីថ្ងៃភាគីជម្លោះទទួលបានកំណត់ហេតុមិនសះជា កម្មវត្ថុនៃបណ្តឹងមិនអាចគិតជាប្រាក់បាន ឬមានតម្លៃលើសពី ៤០០.០០០.០០០ (បួនរយលាន) រៀល លើកលែងតែភាគីជម្លោះព្រមព្រៀងជាឯកច្ឆន្ទកម្រិតតម្លៃកម្មវត្ថុនៃបណ្តឹងមិនឱ្យលើសពី ៤០០.០០០.០០០ (បួនរយលាន) រៀល"[11]។ បន្ថែមពីនេះ ចំពោះពាក្យបណ្តឹងដែលកំពុង ឬត្រូវបានដោះស្រាយដោយមជ្ឈត្តកម្ម ឬតុលាការ ក៏នឹងត្រូវបានធ្វើការបដិសេធដូចគ្នាផងដែរ។

បន្ទាប់ពីការពិនិត្យលើពាក្យបណ្តឹងត្រូវបានបញ្ចប់ អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជានឹងតែងតាំងអ្នកដោះស្រាយវិវាទដែលជាមន្ត្រីរបស់និយ័តករមូលបត្រកម្ពុជា ដែលត្រូវបានចាត់តាំងដោយអគ្គនាយកដើម្បី

[10] ប្រការ២៧ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

[11] ប្រការ១៥ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

ដោះស្រាយវិវាទដែលមាន "សមាសភាព១ (មួយ) រូប ឬ ៣ (បី) រូប តាមសំណើរបស់ប្រធានការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ"[12]។ ក្នុងករណីការដោះស្រាយវិវាទធ្វើឡើងដោយអ្នកដោះស្រាយវិវាទ ៣ (បី) រូប អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ត្រូវចាត់តាំងអ្នកដោះស្រាយវិវាទ ១ (មួយ) រូប ធ្វើជាប្រធានក្រុម។ ចំពោះអ្នកផ្សះផ្សាក៏អាចត្រូវបានចាត់តាំងជាអ្នកដោះស្រាយវិវាទចំពោះវិវាទដែលខ្លួនធ្លាប់បានផ្សះផ្សាផងដែរ។ ទន្ទឹមនឹងនេះ អនុលោមតាមប្រការ៣០ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ក៏បានហាមឃាត់មិនឱ្យអ្នកដោះស្រាយវិវាទអនុវត្តតួនាទីជាអ្នកដោះស្រាយវិវាទក្នុងវិស័យមូលបត្រដូចគ្នាទៅអ្នកផ្សះផ្សាផងដែរ ក្នុងករណីដែលអ្នកដោះស្រាយវិវាទជាបុគ្គលដូចមានកំណត់ក្នុងប្រការ១៤ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ។ សម្រាប់បុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងវិវាទ ឬផលប្រយោជន៍ណាមួយពាក់ព័ន្ធនឹងការដោះស្រាយវិវាទ និងត្រូវបានចាត់តាំងអ្នកដោះស្រាយវិវាទ ដែលមានតួនាទី និងភារកិច្ច ក្នុងការរៀបចំវេទិកាដោះស្រាយវិវាទ ដើម្បីកំណត់នូវចំណុចវិវាទដែលត្រូវដោះស្រាយ និងជួយសម្រួលដល់ភាគីជម្លោះដើម្បីឱ្យឈានទៅរកការសះជាជាដើម។ បន្ថែមពីនេះ អ្នកដោះស្រាយវិវាទ ក៏មានតួនាទី និងភារកិច្ចបន្ថែមទៀត ដូចជាការអនុវត្តមុខងារ និងភារកិច្ចឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននៃការដោះស្រាយវិវាទ ការចេញសេចក្តីសម្រេចលើវិវាទ ព្រមទាំងតួនាទី និងភារកិច្ចផ្សេងទៀតដូចមានកំណត់ក្នុងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យមូលបត្រ។

បន្ទាប់ពីនិយ័តករមូលបត្រកម្ពុជា បានបញ្ចប់នីតិវិធីពាក់ព័ន្ធនឹងចំណាត់ការលើពាក្យបណ្តឹងស្នើសុំការផ្សះផ្សា និងការដោះស្រាយវិវាទរួច អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជានឹងចាប់ផ្តើមបើកនីតិវិធីផ្សះផ្សា និងការដោះស្រាយវិវាទជូនភាគីជម្លោះ ដោយអនុលោមទៅតាមប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាននៅក្នុងវិស័យមូលបត្រ។

### ២.១.២. ដំណើរការនៃការផ្សះផ្សា និងការដោះស្រាយវិវាទ

#### ២.១.២.១. ការផ្សះផ្សាវិវាទ

អនុលោមតាមប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ វិនិយោគិនដែលមានវិវាទក្នុងវិស័យមូលបត្រ ពាក់ព័ន្ធនឹងការទាមទារ ជម្លោះ ឬទំនាស់ពាក់ព័ន្ធនឹងមូលបត្រ ឬការផ្តល់សេវាក្នុងវិស័យមូលបត្រ ភាគីជម្លោះដែលមានវិវាទក្នុងវិស័យមូលបត្រអាចដាក់ពាក្យបណ្តឹងសុំការផ្សះផ្សាវិវាទជូននិយ័តករមូលបត្រកម្ពុជា ដើម្បីធ្វើការផ្សះផ្សា។ ចំពោះដំណើរការផ្សះផ្សាវិវាទក្នុងវិស័យមូលបត្រនឹងប្រព្រឹត្តទៅដោយសម្ងាត់ ក្រោមការសម្របសម្រួលរបស់អ្នកផ្សះផ្សាដែលជាមន្ត្រីរបស់និយ័តករមូលបត្រកម្ពុជា។ ក្នុងករណីដែលពាក្យបណ្តឹងសុំការផ្សះផ្សា

[12] ប្រការ២៧ នៃប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

បានបំពេញត្រឹមត្រូវ និងគោរពតាមលក្ខខណ្ឌដែលបានកំណត់រួចហើយ ភាគីជម្លោះត្រូវចុះកិច្ចព្រមព្រៀងផ្សះផ្សាវិវាទតាមទម្រង់ដែលកំណត់ដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបង់កម្រៃសេវារដ្ឋបាល បង់កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ព្រមទាំងដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សោហ៊ុយចំណាយផ្សេងៗក្នុងដំណើរការផ្សះផ្សា។ អ្នកផ្សះផ្សាវិវាទរបស់និយ័តករមូលបត្រកម្ពុជា ត្រូវអញ្ជើញភាគីជម្លោះទាំងអស់ឱ្យមកចូលរួមក្នុងដំណើរការនៃការផ្សះផ្សាតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ដោយអ្នកផ្សះផ្សា។ ក្នុងករណីដែលភាគីជម្លោះមិនបានចូលរួមក្នុងដំណើរការផ្សះផ្សាតាមការអញ្ជើញលើកទីមួយនោះទេ អ្នកផ្សះផ្សាអាចធ្វើការអញ្ជើញភាគីជម្លោះដែលអវត្តមាន ជាលើកទីពីរ និងបន្តបន្ទាប់តាមការចាំបាច់។ ករណីដែលភាគីជម្លោះណាមួយនៅតែបន្តមិនព្រមមកបង្ហាញខ្លួនចំនួនពីរលើកជាប់ៗគ្នាក្នុងដំណើរការផ្សះផ្សាដោយគ្មានមូលហេតុសមរម្យការផ្សះផ្សាអាចត្រូវចាត់ទុកថាមិនសះជា។ ដំណើរការនៃការផ្សះផ្សានឹង "ត្រូវបញ្ចប់ក្នុងរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកផ្សះផ្សាត្រូវបានចាត់តាំងដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា"[13]។ បន្ទាប់ពីបានបញ្ចប់ដំណើរការនៃការផ្សះផ្សា អ្នកផ្សះផ្សាត្រូវបង្ហាញលទ្ធផលនៃការផ្សះផ្សា ដែលលទ្ធផលនៃការផ្សះផ្សានោះអាចសះជា ឬមិនសះជា។ ក្នុងករណីដែលការផ្សះផ្សាត្រូវបានសះជា ភាគីជម្លោះត្រូវចុះកិច្ចព្រមព្រៀង សះជាជាមួយគ្នា ដែលការព្រមព្រៀងនេះត្រូវធ្វើឡើងនៅចំពោះមុខអ្នកផ្សះផ្សា ហើយក៏ជាការព្រមព្រៀងដែលមានអានុភាពអនុវត្តសម្រាប់ភាគីជម្លោះផងដែរ។

ចំពោះចំណុចនៃវិវាទដែលភាគីជម្លោះមិនបានព្រមព្រៀងគ្នាក្នុងដំណើរការផ្សះផ្សា ត្រូវចាត់ទុកថាមិនសះជា។ ដូច្នេះ អ្នកផ្សះផ្សាត្រូវរៀបចំ និងធ្វើកំណត់ហេតុមិនសះជា ដោយបញ្ជាក់ពីចំណុចដែលភាគីជម្លោះមិនសះជា មូលហេតុ និងព័ត៌មានចាំបាច់ផ្សេងទៀតក្នុងកំណត់ហេតុ។ ក្នុងករណីនេះ ភាគីជម្លោះអាចធ្វើការប្ដឹងបន្ត "ទៅវេទិកាដោះស្រាយវិវាទរបស់របស់និយ័តករមូលបត្រកម្ពុជា ឬវេទិកាមជ្ឈត្តកម្ម ឬតុលាការដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងចំណុចមិនសះជា ដែលអាជ្ញាយុកាលនៃបណ្ដឹងមានរយៈពេល ៩០ ថ្ងៃ គិតពីថ្ងៃភាគីជម្លោះទទួលបានកំណត់ហេតុមិនសះជា បើពុំនោះទេសិទ្ធិប្ដឹងរបស់ភាគីជម្លោះនឹងត្រូវបាត់បង់សម្រាប់សិទ្ធិប្ដឹងបន្ត"[14] ។

### ២.១.២.២. ការដោះស្រាយវិវាទ

អនុលោមតាមប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ វិនិយោគិនដែលមានវិវាទក្នុងវិស័យមូលបត្រ ពាក់ព័ន្ធនឹងការទាមទារ ជម្លោះ ឬទំនាស់ពាក់ព័ន្ធនឹងមូលបត្រ ឬការផ្ដល់សេវាក្នុងវិស័យមូលបត្រ ភាគីជម្លោះអាចដាក់ពាក្យបណ្ដឹងសុំការផ្សះផ្សាមកនិយ័តករមូលបត្រកម្ពុជាដើម្បីធ្វើការផ្សះផ្សា។ បន្ទាប់ពីលទ្ធផលនៃការផ្សះផ្សាអាច សះជា ឬមិនសះជា អាចដាក់ពាក្យបណ្ដឹងសុំការដោះស្រាយវិវាទមកនិយ័តករមូលបត្រកម្ពុជា ឬ

[13] ប្រការ២១ នៃប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

[14] ប្រការ២៣ នៃប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

វេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច នៅចំណុចដែលមិនសះជា ដែលមានអាជ្ញាយុកាលនៃបណ្ដឹងមានរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីជម្លោះទទួលបានកំណត់ហេតុមិនសះជា បើពុំដូច្នោះទេសិទ្ធិប្ដឹងនឹងត្រូវបាត់បង់សម្រាប់ការដាក់ពាក្យបណ្ដឹងសុំការដោះស្រាយវិវាទ។ ករណីភាគីជម្លោះសម្រេចដាក់ពាក្យបណ្ដឹងសុំការដោះស្រាយវិវាទមកនិយ័តករមូលបត្រកម្ពុជា ដោយបានបំពេញពាក្យបណ្ដឹងត្រឹមត្រូវ និងគោរពតាមលក្ខខណ្ឌដែលបានកំណត់ ភាគីជម្លោះត្រូវចុះកិច្ចព្រមព្រៀងដោះស្រាយវិវាទតាមទម្រង់ដែលកំណត់ដោយនិយ័តករមូលបត្រកម្ពុជា និងបង់កម្រៃសេវារដ្ឋបាល សេវាសម្រាប់អ្នកដោះស្រាយវិវាទ ព្រមទាំងដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សោហ៊ុយចំណាយផ្សេងៗ ក្នុងដំណើរការដោះស្រាយវិវាទ មុននឹងចាប់ផ្ដើមដំណើរការដោះស្រាយវិវាទ។ អ្នកដោះស្រាយវិវាទនឹងអញ្ជើញភាគីជម្លោះទាំងសងខាងដើម្បីចូលរួមក្នុងវេទិកាដោះស្រាយវិវាទ ដែលរៀបចំឡើងតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ដោយអ្នកដោះស្រាយវិវាទ។ ក្នុងករណីដែលភាគីជម្លោះមិនបានចូលរួមក្នុងវេទិកាដោះស្រាយវិវាទតាមការអញ្ជើញលើកទីមួយ អ្នកដោះស្រាយវិវាទអាចអញ្ជើញ ទៅភាគីជម្លោះដែលបានអវត្តមានជាលើកទីពីរ។ សម្រាប់នីតិវិធីនៃការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ "មានរយៈពេល ៤៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអ្នកដោះស្រាយវិវាទត្រូវបានចាត់តាំងដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា"[15]។ បន្ទាប់ពីដំណើរការដោះស្រាយវិវាទត្រូវបានបញ្ចប់ អ្នកដោះស្រាយវិវាទនឹងចេញសេចក្ដីសម្រេចស្ដីពីលទ្ធផលនៃការធ្វើការដោះស្រាយវិវាទ ដោយខ្លឹមសារនៃសេចក្ដីសម្រេចនោះមានវិសាលភាពចងកាតព្វកិច្ចអនុវត្តចំពោះភាគីជម្លោះ ដែលជាប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្ដាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលផ្សេងទៀតដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា។ នៅពេលដែលអ្នកដោះស្រាយវិវាទចេញសេចក្ដីសម្រេចស្ដីពីលទ្ធផលនៃការដោះស្រាយវិវាទរួចហើយ អ្នកដោះស្រាយវិវាទត្រូវជូនដំណឹងទៅភាគីជម្លោះ។ បន្ទាប់ពីភាគីជម្លោះទទួលបានការជូនដំណឹង និងទទួលយល់ព្រមអនុវត្តសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទនៃនិយ័តករមូលបត្រកម្ពុជារួចហើយ "ភាគីជម្លោះទាំងអស់ត្រូវចុះហត្ថលេខា ឬផ្ដិតមេដៃ លើកិច្ចព្រមព្រៀងនៅចំពោះមុខអ្នកដោះស្រាយវិវាទយ៉ាងយូរ ៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលភាគីជម្លោះទទួលបានការជូនដំណឹងពីការយល់ព្រមដើម្បីអនុវត្តសេចក្ដីសម្រេច"[16] ។

ក្នុងករណីភាគីជម្លោះជាវិនិយោគិនមិនយល់ព្រមអនុវត្តសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទ ភាគីជម្លោះអាចប្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច។ ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ដែលមិនយល់ព្រមអនុវត្តតាមខ្លឹមសារ

[15] ប្រកាស៣៦ នៃប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

[16] ប្រកាស៣៩ នៃប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ឆ្នាំ២០១៧

នៃសេចក្តីសម្រេចរបស់អ្នកដោះស្រាយវិវាទ ក៏អាចប្តឹងទៅតុលាការមានសមត្ថកិច្ចដើម្បីសុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់និយ័តករមូលបត្រកម្ពុជាបានផងដែរ។

## ២.២. ការបង្ក្រាបការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ ឬជាកន្លែងដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ ដែលមានជាអាទិ៍ មូលបត្រកម្មសិទ្ធិ មូលបត្របំណុល ឧបករណ៍និស្សន្ទ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលកំណត់ថាជាមូលបត្រជាដើម។ ដូច្នេះ ក្នុងករណីដែលវិនិយោគិន ឬសាធារណជនធ្វើការវិនិយោគក្នុងវិស័យមូលបត្រត្រូវប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដែលកើតចេញពីជនឆក់ឱកាសក្នុងការវិនិយោគដើម្បីស្វែងរកផលចំណេញពីការផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ នៅក្នុងទីផ្សារមូលបត្រ។ ដូចនេះ និយ័តករមូលបត្រកម្ពុជាក្នុងនាមជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ នឹងអភិវឌ្ឍន៍វិស័យមូលបត្រមានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត និងចាត់វិធានការទណ្ឌកម្ម ដើម្បីការពារផលប្រយោជន៍សាធារណជន ក៏ដូចជាដើម្បីធានាឱ្យបានការវិនិយោគមួយដែលមានរបៀបរៀបរយ តម្លាភាព សុក្រឹត្យភាព ក្នុងទីផ្សារមូលបត្រ តាមរយៈការកំណត់អត្តសញ្ញាណបទល្មើស និងការប្រមូលភស្តុតាងដើម្បីចាត់វិធានការទណ្ឌកម្មចំពោះបុគ្គលប្រព្រឹត្តល្មើសឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រជាធរមាន។

### ២.២.១. ការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យមូលបត្រដែលបានផ្តល់សិទ្ធិអំណាចជូននិយ័តករមូលបត្រកម្ពុជាក្នុងការធានាឱ្យបាននៅទីផ្សារមួយប្រកបដោយប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់ ពោល គឺការធានាឱ្យមានការប្រកួតប្រជែងមួយដោយត្រឹមត្រូវ និងយុត្តិធម៌ ការពារវិនិយោគិនឱ្យគេចផុតពីអំពើរំលោភបំពាន និងការបោកបញ្ឆោតក្នុងទីផ្សារ ដែលបានបង្កឡើងតាមរយៈការប្រព្រឹត្តអំពើល្មើស ឬបទល្មើស របស់ជនខិលខូច ក៏ដូចជាតួអង្គដែលបានចូលរួមនៅក្នុងវិស័យមូលបត្រ។ ប៉ុន្តែទោះបីជានិយ័តករមូលបត្រកម្ពុជាបានអនុម័តច្បាប់ និងបទប្បញ្ញត្តិសម្រាប់ធ្វើការគ្រប់គ្រងដើម្បីធានាបានប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់ក្នុងទីផ្សារក៏ដោយ ក៏ការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រនៅតែកើតមានឡើងផងដែរ។ សម្រាប់ការប្រព្រឹត្តល្មើសនៅក្នុងវិស័យមូលបត្រអាចត្រូវបានស្តែងឡើងជាអំពើល្មើស ឬបទល្មើស ដែលបានបង្កឡើងដោយតួអង្គដែលបានចូលរួមនៅក្នុងវិស័យមូលបត្រ តាមរយៈការប្រព្រឹត្តកំហុសដោយចេតនា ឬអចេតនា ឬការធ្វេសប្រហែសនឹងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់តួអង្គដែលបានចូលរួមនៅក្នុងវិស័យមូលបត្រ ឬបង្កដោយជនខិលខូចមួយចំនួនដែលឆក់ឱកាសកេងចំណេញដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ។ ដូចនេះ ដើម្បីអាចចាត់វិធានការទណ្ឌកម្មលើករណីប្រព្រឹត្តល្មើសនេះ និយ័តករមូលបត្រកម្ពុជាដែលជានិយ័តករគ្រប់គ្រងវិស័យមូលបត្រ ត្រូវពិនិត្យដោយផ្អែកលើធាតុផ្សំចំនួន ៣ គឺ៖

១- ធាតុផ្សំនីត្យានុកូល សំដៅដល់អំពើ ឬទោសណាមួយដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមានទើបទណ្ឌកម្មអាចអនុវត្តទៅបាន។

២-ធាតុផ្សំសត្យានុម័ត ដែលសំដៅដល់អង្គហេតុ ឬហេតុការណ៍ទាំងឡាយណាដែលបង្កឱ្យមានអាកប្បកិរិយា(អំពើសកម្ម និងអសកម្ម) ណាមួយ។

៣-ធាតុផ្សំអត្តនោម័ត ដែលសំដៅដល់កិរិយាផ្លូវចិត្តរបស់ដែលជនប្រព្រឹត្តល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។

**២.២.១.១. អំពើល្មើស**

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន អំពើល្មើស គឺជាសកម្មភាពល្មើសក្នុងវិស័យមូលបត្រដែលសំដៅដល់អំពើទាំងឡាយណាដែលល្មើសនឹងកាតព្វកិច្ច ឬលក្ខខណ្ឌនៃច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬលក្ខខណ្ឌនៃអាជ្ញាបណ្ណ ការអនុញ្ញាត ការទទួលស្គាល់ក្នុងវិស័យមូលបត្រ ឬសេចក្តីសម្រេចឬការណែនាំរបស់និយ័តករមូលបត្រកម្ពុជា។ អំពើល្មើស ត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យមូលបត្រដែលស្តែងឡើងតាមរយៈការប្រព្រឹត្តល្មើសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬបុគ្គលដែលទទួលបានការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ (ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត) ដែលមានដាក់លក់មូលបត្រ ឬដាក់តម្លៃក្នុងទីផ្សារមូលបត្រ និង/ឬ បុគ្គលសង្ស័យផ្សេងទៀត ដែលប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ។ ក្នុងករណីអំពើល្មើសកើតមានឡើង និយ័តករមូលបត្រកម្ពុជាអាចស៊ើបអង្កេតដើម្បីកំណត់អត្តសញ្ញាណនៃអំពើល្មើសក្នុងការចាត់វិធានការទណ្ឌកម្មដូចជា ទណ្ឌកម្មរដ្ឋបាល និង/ឬពិន័យអន្តរការណ៍ជាដើម។ ចំពោះវិធានការទណ្ឌកម្មរដ្ឋបាលដែលចេញដោយនិយ័តករមូលបត្រកម្ពុជា អាចធ្វើឡើងតាមទម្រង់ដូចមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ ដែលមានដូចជា ការព្រមាន ឬដាស់តឿន ការដឹកនាំកែតម្រង់ ការព្យួរ ឬបណ្តេញបុគ្គលិកជាន់ខ្ពស់ចេញពីមុខតំណែង ការដាក់កម្រិតលើអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ ការព្យួរអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ ឬការដកហូតអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ជាដើម។ បន្ថែមពីលើទណ្ឌកម្មរដ្ឋបាល និយ័តករមូលបត្រកម្ពុជាអាចចាត់វិធានការទណ្ឌកម្មបន្ថែម ដូចជាការផាកពិន័យអន្តរការណ៍ជាប្រាក់ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រព្រឹត្តអំពើល្មើសក្នុងវិស័យមូលបត្រ។ ចំពោះការចាត់វិធានការទណ្ឌកម្មរបស់និយ័តករមូលបត្រកម្ពុជាលើបុគ្គលប្រព្រឹត្តល្មើសនេះ ត្រូវបានចាត់ទុកថា ជាការចាត់វិធានការរបស់អាជ្ញាធរអាណាព្យាបាលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបទលហុក្នុងវិស័យមូលបត្រ។

### ២.២.១.២. បទល្មើស

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន បទល្មើស គឺសំដៅដល់អំពើប្រឆាំងនឹងរដ្ឋ ឬជាអំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងត្រូវផ្តន្ទាទោសតាមការកំណត់ទុកជាមុនក្នុងច្បាប់ និងបទប្បញ្ញត្តិ ឬអាចនិយាយម្យ៉ាងទៀតថាជាអំពើបំពានលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ក្នុងវិស័យមូលបត្របទល្មើស ត្រូវបានសន្មតថាជាបទល្មើសព្រហ្មទណ្ឌ ដែលស្តែងឡើងតាមរយៈសកម្មភាពទាំងឡាយណាបង្កឱ្យមានផលប៉ះពាល់ដល់ទីផ្សារមូលបត្រ ប៉ះពាល់ដល់ផលប្រយោជន៍របស់សាធារណជន និងបានប្រឆាំងនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ ដែលស្តែងឡើងតាមរយៈការប្រព្រឹត្តល្មើសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ឬការទទួលបានការអនុញ្ញាត ឬបុគ្គលដែលទទួលបានការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ (ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត) ដែលមានមូលបត្រដាក់លក់ ឬដាក់តម្លៃក្នុងទីផ្សារមូលបត្រ និង/ឬ បុគ្គលសង្ស័យផ្សេងទៀត ដែលប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ យោងតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន បានកំណត់បទល្មើស ក៏ដូចជាកិរិយាដែលត្រូវបានហាមឃាត់ទាក់ទងនឹងមូលបត្រ រួមមាន៖

១-ការជួញដូរផ្ទៃក្នុង សំដៅដល់ព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងមូលបត្រដែលត្រូវបោះផ្សាយ និងបានបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលព័ត៌មាននោះមិនទាន់ផ្សព្វផ្សាយជាសាធារណៈ ឬជាទូទៅ ក្នុងគោលបំណងប្រើប្រាស់ដោយផ្ទាល់ ឬមិនផ្ទាល់ ឬការផ្តល់ព័ត៌មានដល់បុគ្គលដទៃណាមួយ ឬនីតិបុគ្គលប្រតិស្រុតណាមួយ ដើម្បីជួញដូរមូលបត្ររបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតក្នុងការស្វែងរកផលចំណេញ ឬបញ្ចៀសការខាតបង់ផ្ទាល់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់ខ្លាំងដល់តម្លៃ ឬទិដ្ឋភាពជួញដូរក្នុងទីផ្សារមូលបត្រ។

២-ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ សំដៅដល់សកម្មភាពរបស់បុគ្គលដែលកើតឡើងដោយចេតនា ឬដោយធ្វេសប្រហែលក្តី ដែលអាចបណ្តាលឱ្យមានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុសចំពោះការជួញដូរមូលបត្រ ដែលគេកំពុងជួញដូរលើទីផ្សារមូលបត្រ ឬការធ្វើប្រតិបត្តិការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតនៅលើទីផ្សារមូលបត្រកម្ពុជា ឱ្យនៅថេរ កើនឡើង ឬស្រុតចុះ ជាដើម។

៣-សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស សំដៅដល់សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬព័ត៌មានដែលមានលក្ខណៈនាំឱ្យយល់ខុសធ្ងន់ធ្ងរ ដែលបណ្តាល

ឱ្យសាធារណជនក្នុងព្រះរាជាណាចក្រកម្ពុជា ទិញ ឬលក់មូលបត្រ ឬបណ្តាលឱ្យមានការកើនឡើង ការថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា។

ក្នុងករណីមានការប្រព្រឹត្តល្មើសដូចមានរៀបរាប់ខាងលើ និយ័តករមូលបត្រកម្ពុជាអាចធ្វើការស៊ើបអង្កេតដូចគ្នានឹងការស៊ើបអង្កេតអំពើល្មើសក្នុងវិស័យមូលបត្រដើម្បីកំណត់អត្តសញ្ញាណនៃបទល្មើសនោះ។ បន្ទាប់ពីកំណត់អត្តសញ្ញាណនៃបទល្មើសរួចហើយ និយ័តករមូលបត្រកម្ពុជានឹងបញ្ជូនសំណុំរឿងទៅតុលាការដើម្បីបន្តនីតិវិធីនឹងចាត់វិធានការទណ្ឌកម្មចំពោះជនល្មើសដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ២.២.២ នីតិវិធីស៊ើបអង្កេត និងការពង្រឹងការអនុវត្តច្បាប់

ក្នុងកិច្ចធានាបានប្រសិទ្ធភាពនៃការអភិវឌ្ឍន៍វិស័យមូលបត្រឱ្យមានការរីកចម្រើន ក៏ដូចជាការវិនិយោគក្នុងវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាសណ្តាប់ធ្នាប់នៃការវិនិយោគក្នុងវិស័យមូលបត្រតាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យលើបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ផ្អែកតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ដែលបានផ្តល់នៅសិទ្ធិអំណាចជាច្រើនដល់និយ័តករមូលបត្រកម្ពុជា ដើម្បីអភិវឌ្ឍទីផ្សារឱ្យមានការរីកចម្រើន ក៏ដូចជាការគ្រប់គ្រងក្នុងវិស័យមូលបត្រឱ្យមានដំណើរការល្អប្រសើរប្រកបដោយប្រសិទ្ធភាពខ្ពស់។ បន្ថែមលើនេះ ដើម្បីការពារអ្នកវិនិយោគក្នុងវិស័យមូលបត្រ ច្បាប់បានអនុញ្ញាតឱ្យនិយ័តករមូលបត្រកម្ពុជាមានមុខងារពិសេសមួយចំនួនសម្រាប់ត្រួតពិនិត្យការវិនិយោគទាំងអស់ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រតាមរយៈការឃ្លាំមើល ការស៊ើបអង្កេត និងការប្រមូលភស្តុតាងដើម្បីចាត់វិធានការទណ្ឌកម្មចំពោះបុគ្គលប្រព្រឹត្តខុស ដើម្បីធានាដល់ដំណើរការវិនិយោគឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ។

#### ២.២.២.១. ការស៊ើបអង្កេត

នៅក្នុងដំណើរការនៃការរក្សាសណ្តាប់ធ្នាប់ក្នុងការវិនិយោគ ក៏ដូចជាការការពារផលប្រយោជន៍របស់វិនិយោគិនក្នុងវិស័យមូលបត្រនិយ័តករមូលបត្រកម្ពុជា អាចចាត់វិធានការមួយចំនួនតាមការចាំបាច់ដើម្បីធានាការវិនិយោគមួយដែលមានលក្ខណៈល្អប្រសើរសម្រាប់អ្នកវិនិយោគក្នុងវិស័យមូលបត្រ តាមរយៈការបង្កើតឱ្យមានយន្តការនៃការស៊ើបអង្កេតដើម្បីកំណត់ប្រភេទអំពើល្មើស ឬបទល្មើស និងការកំណត់បុគ្គលប្រព្រឹត្តល្មើសដើម្បីចាត់វិធានការទណ្ឌកម្មស្របនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យមូលបត្រជាធរមាន។ ចំពោះការស៊ើបអង្កេតក្នុងវិស័យមូលបត្រត្រូវធ្វើឡើងតាមរយៈមន្ត្រីស៊ើបអង្កេតរបស់និយ័តករមូលបត្រកម្ពុជា ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដើម្បីស៊ើបអង្កេតអំពើល្មើសក្នុងវិស័យមូលបត្រ ឬបទល្មើសក្នុងវិស័យមូលបត្រ ដើម្បីប្រមូលយកព័ត៌មាន បញ្ជី កំណត់ត្រា របាយការណ៍ ឯកសារ វត្ថុតាង ទិន្នន័យ ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក

និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលមានជាប់សង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើស ឬអំពើល្មើស។ បន្ថែមពីនេះ មន្ត្រីស៊ើបអង្កេតក្នុងវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជាក៏មានភ្នាក់ងារស៊ើបអង្កេតបន្ថែមទៀតដែលជាមន្ត្រីរបស់និយ័តករមូលបត្រកម្ពុជា ដែលមានគុណសម្បត្តិធ្វើជាភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីបំពេញតួនាទីជួយដល់មន្ត្រីស៊ើបអង្កេតក្នុងនីតិវិធីនៃដំណើរការស៊ើបអង្កេតផងដែរ។ ការស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេតនៃនិយ័ត-ករមូលបត្រកម្ពុជាក្នុងវិស័យមូលបត្រនេះ អាចធ្វើឡើងចំពោះ រូបវន្តបុគ្គល ឬបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ឬទទួលបានការអនុញ្ញាត បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលមានមូលបត្រដាក់លក់ ឬដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ និង/ឬ បុគ្គលសង្ស័យផ្សេងទៀតទៅតាមករណីជាក់ស្តែងដែលមានការសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើស ឬអំពើល្មើសក្នុងវិស័យមូលបត្រ។

នៅក្នុងនីតិវិធីនៃការស៊ើបអង្កេតអំពើល្មើស និងបទល្មើសក្នុងវិស័យមូលបត្រ មន្ត្រីស៊ើបអង្កេតរបស់និយ័តករមូលបត្រកម្ពុជា អាចធ្វើកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលជាស្ថាប័នរបស់រដ្ឋដែលមានជាអាទិ៍ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម និងស្ថាប័នដទៃទៀត ក្នុងការស៊ើបអង្កេតបទល្មើស ឬអំពើល្មើសក្នុងវិស័យមូលបត្រ ដើម្បីស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងអំពើមិនសមស្របដែលពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ចំពោះករណីសង្ស័យដើម្បីប្រមូលភស្តុតាង ឬបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចោទប្រកាន់ពីបទល្មើស និង/ឬបញ្ជូនសំណុំរឿងទៅការិយាល័យពង្រឹងការអនុវត្តច្បាប់និងនីតិកម្មនៃនិយ័តករមូលបត្រកម្ពុជា ចំពោះអំពើល្មើសដើម្បីចាត់វិធានការទណ្ឌកម្មតាមផ្លូវច្បាប់ដូចមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យមូលបត្រ។

### ២.២.២.២. ការពង្រឹងការអនុវត្តច្បាប់

ការវិនិយោគក្នុងវិស័យមូលបត្រ គឺជាការវិនិយោគដែលមានលក្ខណៈស្មុគស្មាញ និងមានលក្ខណៈក្មេងខ្ចីសម្រាប់ប្រទេសកម្ពុជាពិសេសគឺសម្រាប់សាធារណជនទូទៅ ក៏ដូចជាវិនិយោគិនក្នុងវិស័យមូលបត្រ។ ដូច្នេះ និយ័តករមូលបត្រកម្ពុជាដែលជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍ ក្នុងវិស័យមូល-បត្រឱ្យមានស្ថេរភាព និងមានការរីកចម្រើន និយ័តករមូលបត្រកម្ពុជា បានដាក់ចេញនូវគោលការណ៍យ៉ាងច្រើនសម្រាប់គ្រប់គ្រងលើវិស័យមូលបត្រតាមរយៈការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ក្នុងកិច្ចគាំពារដល់វិនិយោគិនក្នុងវិស័យមូលបត្រ ដើម្បីធានាឱ្យបានសុវត្ថិភាព តម្លាភាព និងភាពស្មោះត្រង់ក្នុងការវិនិយោគ ក្នុងទីផ្សារមូលបត្រ។ ដូចនេះ និយ័តករមូលបត្រកម្ពុជា អាចដាក់ចេញវិធានការទណ្ឌកម្មណាមួយក្នុងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រតាមរយៈការចាត់វិធានការទណ្ឌកម្មរដ្ឋបាល ដែលមានដូចជា ការចេញលិខិតព្រមានទៅលើបុគ្គលដែលពិនិត្យ

ឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន ឬច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត ឬតាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិដែលតម្រូវឱ្យបុគ្គលដែលប្រព្រឹត្តល្មើសនោះអនុវត្តតាមដូចជាការជួស-ជុលសំណងព្យសនកម្មដែលកើតមានពីសកម្មភាពណាមួយដល់វិនិយោគិនក្នុងវិស័យមូលបត្រ ឬទណ្ឌកម្មផ្សេងទៀតដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងវិស័យមូលបត្រក្នុងកិច្ចធានានៅការវិនិយោគមួយដែលមានតម្លាភាព ភាពស្មោះត្រង់ ឬស្ថានភាពមិនប្រក្រតីណាមួយក្នុងការវិនិយោគក្នុងវិស័យមូលបត្រ។ ក្រៅពីទណ្ឌកម្មជាលិខិតព្រមាន ឬការជួសជុលសំណងព្យសនកម្មនោះ និយ័តករមូលបត្រកម្ពុជាក៏អាចចាត់វិធានការផាកពិន័យអន្តរការណ៍ និង/ឬចាត់វិធានការទណ្ឌកម្មរដ្ឋបាលលើបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនិងលក្ខខណ្ឌនៃច្បាប់ ឬការកំណត់របស់និយ័តករមូលបត្រកម្ពុជា និង/ឬព្យួរជាបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិកគណៈកម្មាការគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់នីតិបុគ្គលមានអាជ្ញាបណ្ណ ឬនីតិបុគ្គលប្រតិស្រុតបានផងដែរ ក្នុងករណីដែលបុគ្គលទាំងនោះបានប្រព្រឹត្តខុសនឹងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានក្នុងវិស័យមូលបត្រ។

ទន្ទឹមនឹងនេះ ក្នុងកិច្ចគាំពារដល់ការវិនិយោគក្នុងវិស័យមូលបត្រនិយ័តករមូលបត្រកម្ពុជា បានធ្វើការកំណត់នៅកិរិយាហាមឃាត់មួយចំនួនលើអ្នកវិនិយោគដែលមានជាអាទិ៍ ការជួញដូរផ្ទៃក្នុង ឬ ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារមូលបត្រ ឬសេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស ឬទណ្ឌកម្មផ្សេងទៀតតាមស្ថានភាពជាក់ស្តែងនៃសង្គម ឬការយល់ឃើញរបស់និយ័តករមូលបត្រកម្ពុជា ដែលយល់ថាចាំបាច់ក្នុងការធានាឱ្យបាននៅការវិនិយោគមួយដែលមានសណ្តាប់ធ្នាប់ តម្លាភាព និងផ្តល់សុវត្ថិភាពដល់វិនិយោគិនដែលចូលរួមក្នុងវិស័យមូលបត្រ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមប្រធានបទខាងលើ ការវិនិយោគក្នុងវិស័យមូលបត្រ គឺជាសញ្ញាណថ្មីមួយសម្រាប់វិនិយោគិន ធ្វើការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការកៀរគរប្រមូលមូលធនមកវិនិយោគក្នុងស្រុក និងក្រៅស្រុក ការបង្កើតបានឱកាសការងារ ការបង្កើនកាលានុវត្តភាពវិនិយោគ និងការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ វិស័យមូលបត្រត្រូវបានកំណត់ថា ជាវិស័យអាទិភាពមួយដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់កម្ពុជាឱ្យកាន់តែមានការរីកចម្រើនប្រកបដោយបរិយាបន្ន នវានុវត្តន៍ និងនិរន្តរភាព។ ក្នុងកិច្ចធានាដល់ដំណើរការវិនិយោគក្នុងវិស័យមូលបត្រ ក៏ដូចជាការការពារផលប្រយោជន៍ដល់វិនិយោគិនដែលបានចូលរួមនៅទីផ្សារមូលបត្រនិយ័តករមូលបត្រកម្ពុជា ដែលជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រ បានដាក់ចេញគោលការណ៍សំខាន់ៗជាច្រើនតាមរយៈការរក្សាឱ្យមានការវិនិយោគមួយប្រកបដោយទំនុកចិត្តពីអ្នកវិនិយោគ ការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ពិសេស គឺការអនុញ្ញាតឱ្យតួអង្គដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មកធ្វើការវិនិយោគនៅទីផ្សារមូលបត្រកម្ពុជា ដែលរួមមាន ប្រតិបត្តិកររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ) ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលចុះបញ្ជី ក្រុមហ៊ុនអន្តរការីមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនចែកចាយលក់មូលបត្រ ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិ) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ភ្នាក់ងាររក្សាសុវត្ថិភាព ក្រុមហ៊ុនផ្តល់សេវាក្នុងវិស័យមូលបត្រ (ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ សវនកម្ម បកប្រែ វាយតម្លៃ) និងតួអង្គពាក់ព័ន្ធផ្សេងទៀតដែលបានចូលរួមនៅទីផ្សារមូលបត្រ។ ដោយតួអង្គនីមួយៗដែលចូលរួមនៅទីផ្សារមូលបត្រ ត្រូវទទួលខុសត្រូវទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ជាពិសេសគឺការធានាដល់ការវិនិយោគមួយដែលមានប្រសិទ្ធភាព តម្លាភាព ភាពស្មោះត្រង់ មិនមានការក្លែងបន្លំណាមួយនៅពេលធ្វើការវិនិយោគដែលបណ្តាលឱ្យប៉ះពាល់ដល់ប្រយោជន៍របស់វិនិយោគិនផ្សេងទៀតឡើយ។ ហើយដើម្បីធានាបានកិច្ចគាំពារដល់វិនិយោគិនក្នុងវិស័យមូលបត្រ រាល់បុគ្គលដែលចូលរួមក្នុងវិស័យមូលបត្រត្រូវតែជាបុគ្គលដែលមានលក្ខណៈសម្បត្តិល្អ ឬមានគុណវុឌ្ឍិដែលមានការទទួលស្គាល់ដោយនិយ័តករមូលបត្រកម្ពុជា និងគោរពតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានកំណត់ក្នុងវិស័យ

មូលបត្រ។ បន្ថែមពីនេះចំពោះដំណើរការនៃការវិនិយោគក្នុងវិស័យមូលបត្រគិតចាប់តាំងពីការចាប់ផ្តើមប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ រហូតដល់ការបញ្ចប់ការប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍របស់និយ័តករមូលបត្រកម្ពុជា ដែលជានិយ័តករតែមួយគត់ក្នុងវិស័យមូលបត្រ។ បន្ថែមលើនេះ ក្នុងករណីបុគ្គល ឬក្រុមហ៊ុន ដែលធ្វើអាជីវកម្មក្នុងវិស័យមូលបត្រ បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិមានកំណត់ និងធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការវិនិយោគឬធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃសាធារណជនដែលចូលរួមក្នុងគម្រោងដោយចេតនាមិនល្អ បុគ្គលនោះនឹងត្រូវទទួលទណ្ឌកម្មដែលកំណត់តាមច្បាប់ និងបទប្បញ្ញត្តិដែលមានក្នុងវិស័យមូលបត្រជាធរមាន រួមមានទណ្ឌកម្មរដ្ឋបាល ការពិន័យអន្តរការណ៍ ឬទណ្ឌកម្មព្រហ្មទណ្ឌ។

ការវិនិយោគក្នុងវិស័យមូលបត្រមិនត្រឹមតែជួយដល់ការអភិវឌ្ឍ និងបង្កើនចំណូលដល់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ថែមទាំងអាចឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ និងវិនិយោគិន ទទួលបានអត្ថប្រយោជន៍ច្រើនផងដែរ ដោយក្នុងនោះសម្រាប់ក្រុមហ៊ុនអាចទទួលបានដើមទុនបន្ថែម ទំនុកចិត្តពីដៃគូ និងអតិថិជន ក្រុមហ៊ុនទទួលបានការគ្រប់គ្រងតាមស្តង់ដាតម្រូវ លទ្ធភាពក្នុងការរីកចម្រើន ការទទួលបានការលើទឹកចិត្តពន្ធដារ ហើយក្រុមហ៊ុននឹងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ចំណែកឯវិនិយោគិនវិញ ក៏អាចធ្វើការស្វែងកប្រាក់ចំណេញ ឬក្លាយជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនបោះផ្សាយ (សម្រាប់ការទិញ-លក់មូលបត្រកម្មសិទ្ធិ) មានលុយតិចតួចក៏អាចវិនិយោគបាន ព្រមទាំងទទួលបានអត្ថប្រយោជន៍ផ្សេងទៀតដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទស្តីពី៖ "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" នាងខ្ញុំបានពិនិត្យឃើញថាវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជាពុំទាន់មានការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនដល់សាធារណជននៅឡើយទេ ពិសេសអ្នកដែលរស់នៅតាមតំបន់ដាច់ស្រយាលឬនៅតាមតំបន់ទីជនបទ។ ទន្ទឹមនឹងនេះវិស័យមូលបត្រ គឺជាវិស័យមួយដែលមានវិធានស្មុគស្មាញច្រើន ដូច្នេះហើយទើបបង្កជាផលវិបាកដល់សាធារណជនទូទៅពាក់ព័ន្ធនឹងការស្វែងយល់អំពីចំណេះដឹងផ្នែកច្បាប់និងបទប្បញ្ញត្តិនៅក្នុងវិស័យមូលបត្រ ក៏ដូចជាអាចបង្កជាហានិភ័យខ្ពស់ក្នុងការវិនិយោគ ឬអាចងាយរងគ្រោះក្នុងការបោក-បញ្ឆោតពីជនខិលខូចមួយចំនួន។

ម្យ៉ាងវិញទៀត នៅពេលដែលនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវសរសេរសារណាប្រធានបទស្តីពី៖ "**កិច្ចគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**" នាងខ្ញុំសង្កេតឃើញថាទីផ្សារមូលបត្រកម្ពុជាមានភាពស្មុគស្មាញដែលទាមទារឱ្យមានអ្នកចូលរួមក្នុងទីផ្សារត្រូវតែមានជំនាញ និងចំណេះដឹងខ្ពស់។ ដោយមើលឃើញពីចំណុចខ្វះខាតមួយចំនួនមានរៀបរាប់ខាងលើ ទើបនាងខ្ញុំសូមសំណូមពរឱ្យនិយ័តករមូលបត្រកម្ពុជា គួរ៖

១-រៀបចំការបណ្តុះបណ្តាលដល់តួអង្គដែលចូលរួមនៅទីផ្សារមូលបត្រ តួអង្គពាក់ព័ន្ធ និងសាធារណជនឱ្យបានទូលំទូលាយ។

២-រៀបចំកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នរដ្ឋដែលពាក់ព័ន្ធ ឱ្យយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងការគ្រប់គ្រង ត្រួតពិនិត្យ លើតួអង្គដែលចូលរួមនៅទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព តម្លាភាព និងសណ្តាប់-ធ្នាប់ធ្វើការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យមូលបត្រ គួរតែបើកឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនទូទៅ។

៣-រៀបចំមន្ត្រីជំនាញដើម្បីធ្វើការត្រួតពិនិត្យ តាមដាន និងធ្វើការវាយតម្លៃសកម្មភាពផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រដែលមានដូចជាច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាបានប្រសិទ្ធភាព តម្លាភាព និងសណ្តាប់ធ្នាប់ទីផ្សារមូលបត្រ។

៤-ដាក់ចេញកម្រងបទប្បញ្ញត្តិ និងសន្ទានុក្រមគតិយុត្តពាក់ព័ន្ធនឹងវិស័យមូលបត្រលើប្រព័ន្ធឌីជីថលដែលកំពុងមានការពេញនិយមនាពេលបច្ចុប្បន្ន តាមរយៈការដាក់ឱ្យដំណើរការតាម Web-Based ឬជាកម្មវិធី (Application) ដើម្បីបង្កភាពងាយស្រួលដល់សិស្ស និស្សិត បញ្ញវន្ត អ្នកសិក្សាស្រាវជ្រាវ វិនិយោគិនមូលបត្រ និងសាធារណជនទូទៅក្នុងការទាញយក (Download) មកធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមដើម្បីជាចំណេះដឹងក្នុងការសិក្សាស្រាវជ្រាវ ក៏ដូចជាសម្រាប់ការវិនិយោគវិស័យមូលបត្រនេះ។

៥-ធ្វើទំនើបកម្មលើគេហទំព័រផ្លូវការរបស់និយ័តករមូលបត្រកម្ពុជាតាមរយៈការធ្វើឱ្យមានភាពទាក់ទាញ និងមានព័ត៌មានគ្រប់ជ្រុងជ្រោយ ពិសេសគួរបង្កើតឱ្យមានជាកម្មវិធី Live Chat ដែលមានក្រុមការងាររបស់និយ័តករមូលបត្រកម្ពុជានៅប្រចាំការ  ដើម្បីទទួលបន្ទុកការឆ្លើយតបសាររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ និងសាធារណជនទូទៅ ដែលមានជាចម្ងល់ ឬសំណួរផ្សេងៗ អាចធ្វើការសាកសួរ និងឆ្លើយតបត្រឡប់មកវិញបានភ្លាមៗ ហើយអ្វីដែលសំខាន់បំផុតនោះ គឺការរាយការណ៍ពីព័ត៌មាននៃការឆបោកផ្សេងៗជូននិយ័តករមូលបត្រកម្ពុជា ដើម្បីអាចឱ្យនិយ័តករមូលបត្រកម្ពុជា ចាត់វិធានការ និងដោះស្រាយបានទាន់ពេលវេលា។

៦-ធ្វើការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាឱ្យមានលក្ខណៈទូលំទូលាយដល់សាធារណជន វិនិយោគិន និងតួអង្គពាក់ព័ន្ធ។

៧-រៀបចំកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នដែលជាដៃគូអភិវឌ្ឍន៍ទាំងក្នុង និងក្រៅស្រុក ដើម្បីធ្វើការបណ្តុះបណ្តាលធនធានមនុស្ស និងផ្តល់ឯកសារផ្សេងៗ ដែលជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិឱ្យមានប្រសិទ្ធភាពខ្ពស់។

បន្ថែមពីនេះ សម្រាប់វិនិយោគិន ឬសាធារណជនទូទៅដែលមានបំណងចង់វិនិយោគក្នុងវិស័យមូលបត្រមុននឹងសម្រេចចិត្តវិនិយោគ គួរធ្វើការស្រាវជ្រាវពីក្រុមហ៊ុន និងទីផ្សារឱ្យបានល្អិតល្អន់ជាមុន ដើម្បីកាត់បន្ថយហានិភ័យ និងបង្កើនលទ្ធភាពចំណេញ ដោយសិក្សាទៅលើ៖

១- ការសិក្សាស្វែងយល់ពីអាជីវកម្មរបស់ក្រុមហ៊ុន។

២- ការវិភាគលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

៣- ការព្យាករណ៍ពីហានិភ័យនៃផ្សារហ៊ុនដែលអាចជួបប្រទះនាពេលអនាគត។

៤- ការស្វែងយល់ពីការបង់ពន្ធនានាលើការវិនិយោគមូលបត្រ។

៥- ការជ្រើសរើសក្រុមហ៊ុនមូលបត្រឱ្យបានត្រឹមត្រូវ។

៦- ការជ្រើសរើសប្រភពព័ត៌មានដែលប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់

- ព្រះរាជក្រមលេខ នស/ រកម/០១២១/00៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ព្រះរាជក្រមលេខ នស/ រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន

## ២. អនុក្រឹត្យ

- អនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អនុក្រឹត្យលេខ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន

## ៣. ប្រកាស

- ប្រកាសលេខ០១១ គ.ម.ក ចុះថ្ងៃទី10 ខែធ្នូ ឆ្នាំ២០១១ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ប្រកាសលេខ០០៤/១៥ គ.ម.ក./ ប្រក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- ប្រកាសលេខ០០៥/១៥ គ.ម.ក./ ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ប្រកាសលេខ០០៩/១៧ គ.ម.ក./ ប្រក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- ប្រកាសលេខ០១២/១៧ គ.ម.ក./ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ
- ប្រកាសលេខ០០១/១៨ គ.ម.ក./ ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ
- ប្រកាសលេខ០០៣/១៨ គ.ម.ក./ ប្រក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម
- ប្រកាសលេខ០០៧/១៨ គ.ម.ក./ ប្រក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម
- ប្រកាសលេខ០៣៥ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម

## ៤. ផ្សេងៗ

- https://www.serc.gov.kh/khmer/index.php
- http://www.csx.com.kh/main.do?lang=kh

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា

SECURITIES AND EXCHANGE REGULATOR OF CAMBODIA

លេខ:.............................ន.ម.ក.

# ទម្រង់

# របាយការណ៍អាជីវកម្មប្រចាំត្រីមាសទី..........ឆ្នាំ..............

# សម្រាប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ

Form of Quarterly Business Report

For Firm Providing Audit Service in the Securities Sector

## ក.ព័ត៌មានដែលត្រូវរាយការណ៍

A: Information Reporting

**ផ្នែកទី១ : ព័ត៌មានទូទៅរបស់ក្រុមហ៊ុន**

Section 1 : Overview of Business

១- នាមករណ៍ក្រុមហ៊ុន÷ ...........................................................................................

Company's Name

- អាសយដ្ឋាន÷ ...........................................................................................

Company's Address

- ទូរសព្ទ÷ ...........................................................................................

Phone

- ទូរសារ÷ ...........................................................................................

Fax

- អ៊ីម៉ែល÷ ...........................................................................................

E-mail

- អត្តលេខទទួលស្គាល់ពី **ន.ម.ក.** ÷ ...........................................................................................

Accredited Number at SERC

- សុពលភាពទទួលស្គាល់ពី **ន.ម.ក.** ÷ ...........................................................................................

Validation of Accreditation at SERC

២- សវនករឯករាជ្យ

External Auditors

- ព័ត៌មានរបស់សវនករឯករាជ្យដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.**

Information of Accredited External Auditors from the SERC

| គោត្តនាម និងនាម<br>Surname and Name | ជាអក្សរឡាតាំង<br>In Latin | ភេទ<br>Gender | សញ្ជាតិ<br>Nationality | អត្តលេខទទួលស្គាល់ពី **ន.ម.ក.**<br>Accredited Number at SERC | សុពលភាពទទួលស្គាល់ពី **ន.ម.ក.**<br>Validation of Accreditation at SERC |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

- សវនករឯករាជ្យដែលក្រុមហ៊ុនផ្តល់សិទ្ធិចុះហត្ថលេខាលើរបាយការណ៍ហិរញ្ញវត្ថុ

External auditors empowered by company to sign on financial statements

| គោត្តនាម និងនាម<br>Surname and Name | ជាអក្សរឡាតាំង<br>In Latin | ភេទ<br>Gender | សញ្ជាតិ<br>Nationality | អត្តលេខទទួលស្គាល់ពី **ន.ម.ក.**<br>Accredited Number at SERC | សុពលភាពទទួលស្គាល់ពី **ន.ម.ក.**<br>Validation of Accreditation at SERC |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

៣- បុគ្គលិក

Personnel

| ចំនួនបុគ្គលិកផ្នែកសេវាសវនកម្ម<br>Number of Personnel in Audit Service | ចំនួនបុគ្គលិកផ្នែកសេវាពន្ធ<br>Number of Personnel in Tax Service | ចំនួនបុគ្គលិកផ្នែកសេវាប្រឹក្សាយោបល់<br>Number of Personnel in Advisory Service | ចំនួនបុគ្គលិកផ្នែកសេវាផ្សេងៗ<br>Number of Personnel in Other Service |
|---|---|---|---|
| | | | |

## ៤-ការពិពណ៌នាសង្ខេបអំពីសេវាសវនកម្ម និងសេវាមិនមែនសវនកម្ម

Outline of Audit Services and Non-audit Services

-សេវាសវនកម្ម÷ ..........................................................................................

Audit Service

..........................................................................................

..........................................................................................

-សេវាពន្ធ÷ ..........................................................................................

Tax Service

..........................................................................................

..........................................................................................

-សេវាប្រឹក្សាយោបល់÷ ..........................................................................................

Advisory Service

..........................................................................................

..........................................................................................

-សេវាផ្សេងៗ÷ ..........................................................................................

Other Services

..........................................................................................

..........................................................................................

## ៥-ការពិពណ៌នាអំពីសកម្មភាពប្រតិបត្តិការធុរៈកិច្ច

Describe about Business Operation Activities

-ក្រមសីលធម៌វិជ្ជាជីវៈ÷ ..........................................................................................

Professional Ethics

..........................................................................................

..........................................................................................

-ធនធានមនុស្ស÷ ..........................................................................................

Human Resources

..........................................................................................

..........................................................................................

-គោលការណ៍ និងនីតិវិធីក្នុងការចុះកិច្ចសន្យាជាមួយអតិថិជន÷ ..........................................................................................

Policies and Procedures for Acceptance and Continuance of Clients and Engagement

..........................................................................................

..........................................................................................

## ៦-វិធីសាស្ត្រដែលផ្តល់នូវការប្រតិបត្តិកិច្ចសន្យាប្រកបដោយប្រសិទ្ធភាព÷ ..........................................................................................

Methodology which Delivers Effective Engagement Performance

..........................................................................................

..........................................................................................





៧- ការតាមដានការអនុវត្ត និងការត្រួតពិនិត្យគុណភាពលើការអនុវត្តស្តង់ដា÷ ....................................

Performance Monitoring and Quality Control over the Standard Implementation

..............................................................................................................................................

..............................................................................................................................................

៨- សម្ព័ន្ធភាពរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដទៃទៀត÷ ...................................

Alliance with Other Firms Providing Audit Service and External Auditors

..............................................................................................................................................

..............................................................................................................................................

## ផ្នែកទី២ : ព័ត៌មានពាក់ព័ន្ធនឹងភាគហ៊ុនិក អភិបាល និងបុគ្គលិកជាន់ខ្ពស់

Section 2 : Information Concerning Shareholder Director and Senior Staff

១- ភាគហ៊ុនិក

Shareholders

| គោត្តនាម និងនាម<br>Surname and Name | ជាអក្សរឡាតាំង<br>In Latin | ចំនួនភាគហ៊ុនកាន់កាប់<br>Number of Share held |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

២- ក្រុមប្រឹក្សាភិបាល

Board of Directors

| គោត្តនាម និងនាម<br>Surname and Name | ជាអក្សរឡាតាំង<br>In Latin | មុខតំណែង<br>Position |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

៣-អភិបាល និងបុគ្គលិកជាន់ខ្ពស់
Director and Senior Staffs

| គោត្តនាម និងនាម<br>Surname and Name | ជាអក្សរឡាតាំង<br>In Latin | មុខតំណែង<br>Position |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

៤-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល (ប្រសិនមាន)÷ ..................................................
Other Committees of the Board of Director (If Any)

**ផ្នែកទី៣ : ព័ត៌មានពាក់ព័ន្ធកិច្ចសន្យាការងារក្នុងវិស័យមូលបត្រ**
Section 3 : Information Concerning Contracts in the Securities Sector

១-ចំនួនអតិថិជនផ្នែកសេវាសវនកម្មសរុប÷ ..............................................................................
Number of Clients in Audit Services

២-ចំនួនអតិថិជនផ្នែកសេវាមិនមែនសវនកម្មសរុប÷ ...................................................................
Number of Clients in Non-audit Services

៣-ផ្នែកសេវាសវនកម្ម
Audit Service

-ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
Issuers

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | ប្រភេទអាជីវកម្ម<br>Type of Business | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

-បុគ្គលចុះបញ្ជីលក់មូលបត្រ

Listed Entities

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនមូលបត្រ

Securities Firms

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ

Financial Advisory Firm

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ

Investment Advisory Firm

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនសមភាគីកណ្តាល

Central Counterparties

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនឈ្មួញជើងសារឧបករណ៍និស្សន្ទ

Derivative Brokers

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

- ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ
Funds Managers

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស
Trustees

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនអភិបាលមូលនិធិ
Funds Administrators

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ

Clearance and Settlement Facility Operators

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ប្រតិបត្តិកររក្សាទុកមូលបត្រ

Securities Depository Operators

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ប្រតិបត្តិករទីផ្សារមូលបត្រ

Securities Market Operators

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

Distribution

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

Cash Settlement Agent

| នាមករណ៍ក្រុមហ៊ុន<br>Company's Name | ជាអក្សរឡាតាំង<br>In Latin | សវនករឯករាជ្យទទួលបន្ទុក<br>Responsible External Auditor |
|---|---|---|
